២០១៧

របាយការណ៍ប្រចាំឆ្នាំ

ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី
ÆON SPECIALIZED BANK (CAMBODIA) PLC.

AEON CARD
នេះជាអ្វីដែលអ្នកត្រូវការ

មាតិការ

សង្ខេបព័ត៌មានហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៧	4
សារពីគណៈគ្រប់គ្រង	5
ក្រុមប្រឹក្សាភិបាល	6
តារាងរចនាសម្ព័ន្ធចាត់តាំង	8
ប្រវត្តិអាជីវកម្ម	9
សង្ខេបព័ត៌មានអាជីវកម្មសំខាន់ៗឆ្នាំ ២០១៧	10
ទស្សនៈវិស័យអាជីវកម្មឆ្នាំ ២០១៨	11
ការគ្រប់គ្រងផ្ទៃក្នុង	12
ទំនួលខុសត្រូវផ្នែកសង្គមរបស់ក្រុមហ៊ុន	13
របាយការណ៍របស់សវនកម្មឯករាជ្យ	14
របាយការណ៍ហិរញ្ញវត្ថុ	16

បណ្តាញនៃសម្ព័ន្ធក្រុមហ៊ុនអ៊ីអនហ្វាយនែនសលសីរីស

"ជួយលើកកម្ពស់ជីវភាពរស់នៅរបស់អតិថិជន
និងធ្វើឲ្យពួកគាត់ទទួលបាននូវកាលានុវត្តភាពនាពេលអនាគតជាអតិបរមា
តាមរយៈការប្រើប្រាស់ឥណទានប្រកបដោយប្រសិទ្ធិភាពខ្ពស់"

សង្ខេបព័ត៌មានហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៧

សាវតារបស់យើង

ក្រុមហ៊ុនយើង ត្រូវបានចុះបញ្ជីជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានម្រិត នៅប្រទេសកម្ពុជានៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១ ក្រោមបញ្ជីការលេខ Co.២៣៨០E/២០១១ ចេញដោយក្រសួងពាណិជ្ជកម្ម។ នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១១ យើងបានទទួលអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជា។ ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ យើងជាអ្នកនាំមុខគេទីមួយក្នុងទីផ្សារកម្ពុជា ដែលផ្តល់ជូនអតិថិជននូវសេវាបង់រំលស់ ដោយមិនទាមទារឲ្យមានទ្រព្យធានា ដូចជាផលិតផលប្រើប្រាស់ក្នុងផ្ទះ ម៉ូតូ ទូរស័ព្ទដៃ កម្ចីផ្តាល់ខ្លួន និងសម្ភារៈកសិកម្ម។

នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ យើងទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារឯកទេស ពីធនាគារជាតិនៃកម្ពុជា។ បន្ទាប់មក យើងបានកម្លាយខ្លួនទៅជាធនាគារឯកទេស និងចាប់ផ្តើមពង្រីកអាជីវកម្មរបស់យើងដោយចេញប័ណ្ណឥណទានជូនអតិថិជន។

ឆ្នាំ ២០១៧ ក្រុមហ៊ុន AEON Thana Sinsap (Thailand) Pcl. ដែលជាក្រុមហ៊ុនបានចុះឈ្មោះក្នុងទីផ្សារភាគហ៊ុនប្រទេសថៃ កាន់កាប់ភាគហ៊ុនចំនួន ៨០% ហើយភាគហ៊ុនចំនួន ២០% ផ្សេងទៀតកាន់កាប់ដោយក្រុមហ៊ុន AEON Financial Service Co., Ltd. ដែលជាក្រុមហ៊ុនបានចុះឈ្មោះក្នុងទីផ្សារភាគហ៊ុនប្រទេសជប៉ុន។

ទិន្នន័យហិរញ្ញវត្ថុសំខាន់

ការលក់សរុប (ឯកតា: '000 ដុល្លារ)



ប្រាក់ចំណូលសរុប (ឯកតា: '000 ដុល្លារ)



ទ្រព្យសកម្មសរុប (ឯកតា: '000 ដុល្លារ)



គណនេយ្យទទួល (ឯកតា: '000 ដុល្លារ)



ចំនួនហាងដៃគូ (ឯកតា: ហាងដៃគូអាជីវកម្ម)



ចំនួនពាក្យស្នើសុំ (ឯកតា: អតិជន)



សារពីគណៈគ្រប់គ្រង

លោក Taketo Ando
អនុប្រធានក្រុមប្រឹក្សាភិបាលនិងជាអគ្គនាយក

យើងសូមនាំមកនូវកម្មវិធីលើទូរស័ព្ទដៃស្មាត់ហ្វូន “AEON Wallet Cambodia” ដែលមានមុខងារសម្រាប់ទូទាត់សងប្រាក់ និងផ្ទេរប្រាក់ដោយប្រើប្រាស់នូវលេខសម្ងាត់ QR Code។ ធនាគារឯកទេស អ៊ីអនបានចាប់ផ្តើមសេវាកម្មរូបិយប័ណ្ណអេឡិចត្រូនិកជាមួយរូបិយប័ណ្ណក្នុងស្រុកនៅក្នុងទីផ្សារកម្ពុជា ដែលមានភាព “លឿន សាមញ្ញ និងងាយស្រួល”។

ធនាគារឯកទេសអ៊ីអន(ខេមបូឌា)ភីអិលស៊ីត្រូវបានបង្កើតឡើងក្នុងប្រទេសកម្ពុជានាខែតុលា ឆ្នាំ២០១១ ក្រោមឈ្មោះជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដោយមិនមានទ្រព្យធានា។ យើងបានទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មធនាគារឯកទេសពីធនាគារជាតិ នៃកម្ពុជានៅខែតុលាឆ្នាំ ២០១៥ ហើយបន្ទាប់ពីនោះមកយើងបានចាប់ផ្តើមផ្តល់ជូននូវសេវាប័ណ្ណឥណទានដោយមិនចាំបាច់មានទ្រព្យធានាលើកដំបូងបង្អស់ក្នុងប្រទេសកម្ពុជាចាប់ពីខែមេសាឆ្នាំ២០១៦រហូតមក។គោលបំណងរបស់យើងគឺផ្តល់ជូនអតិថិជននូវសាវាកម្មហិរញ្ញវត្ថុ ដ៏មានភាពងាយស្រួលរួមទាំងអត្ថប្រយោជន៍នានាព្រមទាំងបុព្វសិទ្ធិនានានៅតាមបណ្តាផ្សារទំនើបដែលជាសម្ព័ន្ធក្រុមហ៊ុនរបស់អ៊ីអន។ក្នុងឆ្នាំ២០១៧យើងបានពង្រីកដែនអាជីវកម្មសេវាប័ណ្ណអ៊ីអនទៅកាន់សាខានៅតាមបណ្តាលខេត្តចំនួន ៣បន្ថែមទៀតរួមមានសាខាខេត្តសៀមរាបខេត្តបាត់ដំបង និងខេត្តកំពង់ចាម ដើម្បីចេញប័ណ្ណឥណទានជូនអតិថិជនបង់រំលស់ និងដៃគូសហការណ៍អាជីវកម្មរបស់យើង។ ជាលទ្ធផលប័ណ្ណឥណទានអ៊ីអនចំនួន ២២.៥០៩ ប័ណ្ណ ត្រូវបានផ្តល់ជូនអតិថិជន។

សម្រាប់ឆ្នាំ ២០១៨ យើងនឹងនាំមកនូវរូបិយប័ណ្ណអេឡិចត្រូនិកលើកម្មវិធីលើទូរស័ព្ទដៃស្មាតហ្វូនជាមួយសេវាទូទាត់សងប្រាក់និងសេវាផ្ទេរប្រាក់ជារូបិយវត្ថុជាតិប្រាក់រៀលខ្មែរ ដោយប្រើប្រាស់ QR Code ក្នុងគោលបំណងដើម្បីលើកកម្ពស់ប្រាក់រៀលខ្មែរ ហើយដែលនឹងដាក់ឲ្យដំណើរការក្នុងត្រីមាសទី២នៃឆ្នាំ២០១៨បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតិពីធនាគារជាតិនៃកម្ពុជា។ ផលិតផលជាសេវាទូទាត់សងប្រាក់ជាមួយប្រាក់រៀលខ្មែរ និងដែលមានភាព “លឿន សាមញ្ញ និងងាយស្រួល”។ អតិថិជនអាចទិញទំនិញ និងសេវាផ្សេងៗនៅតាមហាងលក់ទំនិញ ហាងកាហ្វេ និងភោជនីយដ្ឋាននានា ដោយប្រើប្រាស់កម្មវិធីរូបិយប័ណ្ណអេឡិចត្រូនិក លើទូរស័ព្ទដៃស្មាត់ហ្វូនរបស់យើង។ លើសពីនេះទៅទៀតអតិថិជនអាចពិនិត្យមើលសមតុល្យសាច់ប្រាក់ និងប្រតិបត្តិការមុនរបស់ខ្លួន និងធ្វើការផ្ទេរប្រាក់ជាមួយម្ចាស់គណនីផ្សេងទៀត។ កម្មវិធីនេះបានធ្វើទំនើបកម្មជីវភាពរស់នៅប្រចាំថ្ងៃរបស់អតិថិជនដោយមិនចាំបាច់កាន់សាច់ប្រាក់ក្នុងដៃនិងបង្កើនសុវត្ថិភាពជូនអតិថិជនផងដែរ។ អត្ថប្រយោជន៍ដទៃទៀតគឺកម្មវិធីសន្សំពិន្ទុ។ ទិញទំនិញកាន់តែច្រើននោះអតិថិជននឹងទទួលបានពិន្ទុកាន់តែច្រើនក្នុងគណនីនៃកម្មវិធីរូបិយប័ណ្ណអេឡិចត្រូនិករបស់លោកអ្នក។

ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី ជាមួយបំណងប្រាថ្នាសម្រាប់អភិវឌ្ឍន៍ប្រទេសកម្ពុជា យើងផ្សព្វផ្សាយសេវាកម្មដែលប្រើប្រាស់បច្ចេកវិទ្យាគ្មានក្រដាស់ប្រាក់ ជាមួយនឹងសេវាកម្មដែលមានសុវត្ថិភាព សន្តិសុខ និងអត្ថប្រយោជន៍ជាច្រើន ដើម្បីបង្កើនជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងប្រទេសកម្ពុជា និងប្រជាជនក្នុងប្រទេសក្នុងតំបន់អាស៊ីផ្សេងទៀត។

ជាចុងបញ្ចប់ យើងខ្ញុំសូមថ្លែងអំណគុណដល់ប្រជាជនកម្ពុជា និងធនាគារជាតិនៃកម្ពុជា រួមទាំងក្រសួងពាក់ព័ន្ធនានាសម្រាប់ការជួលគាំទ្រដល់យើងខ្ញុំរហូតមក។

安藤 武人

លោក. Taketo Ando
Vice-Chairman of the Board
and Managing Director

ក្រុមប្រឹក្សាភិបាល

លោក Kiyoyasu Asanuma

មុខតំណែង: ប្រធានក្រុមប្រឹក្សាភិបាល
ឆ្នាំកំណើត: ១៩៦០
កម្រិតវប្បធម៌: បរិញ្ញាបត្រទេសចរណ៍ នៅវិទ្យាស្ថាន ប្រទេសជប៉ុន

លោក Taketo Ando

មុខតំណែង: អនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយកនៃ AEON Specialized Bank (Cambodia) Plc
ឆ្នាំកំណើត: 1967
កម្រិតវប្បធម៌: មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម សាកលវិទ្យាល័យ Senshu ប្រទេសជប៉ុន

លោក Keiichi Nambu

មុខតំណែង: នាយកប្រតិបត្តិ
ឆ្នាំកំណើត: ១៩៧២
កម្រិតវប្បធម៌: បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច នៅសាកលវិទ្យាល័យ Takasaki City ប្រទេសជប៉ុន

២០១៦-បច្ចុប្បន្ន
ប្រធានក្រុមប្រឹក្សាភិបាលនៃ AEON Specialized Bank (Cambodia) Plc.

២០១៦-បច្ចុប្បន្ន
ប្រធានក្រុមប្រឹក្សាភិបាលនិងជាអគ្គនាយកនៃ AEON Thana Sinsap (Thailand) Pcl.

២០១៤-២០១៦
នាយកនៃនាយកដ្ឋានផ្នែកលក់ នៃ AEON Credit Service Co.,Ltd.

២០១១-២០១៤
នាយកនៃ ACS Credit Management Co., Ltd.

២០០៧-២០១១
ប្រធានផ្នែកប្រតិបត្តិការអាជីវកម្មនៃ AEON Credit Service Co.,Ltd.

២០០៥-២០០៧
ប្រធានគ្រប់គ្រងទូទៅនៃអង្គភាពប្រតិបត្តិការពាណិជ្ជកម្មនៃ AEON Credit Service Co.,Ltd.

២០០២-២០០៥
ប្រធានគ្រប់គ្រងទូទៅនៃនាយកដ្ឋានគ្រប់គ្រងឥណទាននៃ AEON Credit Service Co.,Ltd.

២០១៧-បច្ចុប្បន្ន
អនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយកនៃ AEON Specialized Bank (Cambodia) Plc

២០១៥-២០១៧
អគ្គនាយកនៃ, ACS Servicing (Thailand) Co., Ltd.

២០១៤-២០១៥
នាយកប្រតិបត្តិនៃ AEON Thana Sinsap (Thailand) Pcl

២០១៣-២០១៤
ប្រធានក្រុមគម្រោងនៃ Makuhari-Shintoshin Branch Project, AEON CreditService Co., Ltd.

២០១២-២០១៣
ប្រធានភូមិភាគខាងត្បូងតំបន់ Kanto នៃ, AEON Credit Service Co., Ltd.

២០១៦-បច្ចុប្បន្ន
នាយកប្រតិបត្តិនៃ AEON Specialized

២០១២-២០១៦
ប្រធានការិយាល័យស្នាក់ការនៃ AEON Credit Service India Private limited ប្រចាំនៅប្រទេសឥណ្ឌា

២០១១-២០១២
ប្រធានការិយាល័យតំណាងនៃ AEON Credit Service India Private limited ប្រចាំនៅប្រទេសឥណ្ឌា

២០០៨-២០១១
បុគ្គលិកផ្នែកទំនាក់ទំនងក្រៅប្រទេសនៃ AEON Credit Service Co., Ltd

អ្នកប្រឹក្សា

លោក អោម សេដបូរ៉ា

មុខតំណែង: អភិបាលឯករាជ្យ
ឆ្នាំកំណើត: ១៩៧៧
កម្រិតវប្បធម៌: សញ្ញាបត្រថ្នាក់អនុបណ្ឌិត ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសកលវិទ្យាល័យ Preston សហរដ្ឋអាមេរិក

២០១៧-បច្ចុប្បន្ន
ប្រធាន KOH RONG LOVE RESORT

២០១៥-បច្ចុប្បន្ន
ស្ថាបនិក និងជាប្រធាននៃវិទ្យាស្ថាន ស៊ីអ៊ីអូ (CEO Institute) អតីតវិទ្យាស្ថានគុណភាពការងារកម្ពុជា

២០១៥-បច្ចុប្បន្ន
ស្ថាបនិក និងជាប្រធាននៃ CEO Master Club

២០១៥-បច្ចុប្បន្ន
ស្ថាបនិក និងជានាយកនៃ THORONI Real Estate Co., Ltd.

២០១៥-បច្ចុប្បន្ន
ស្ថាបនិក និងជានាយក នៃស៊ីអ៊ីជី ខេមបូឌា ម.ក CEG (Cambodia) Plc.

២០១៤-បច្ចុប្បន្ន
អភិបាលឯករាជ្យនៃធនាគារអភិវឌ្ឍន៍ជនបទ (RDB)

២០១៣-បច្ចុប្បន្ន
អភិបាលឯករាជ្យនៃ ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA)

២០១៣-បច្ចុប្បន្ន
សហស្ថាបនិក និងជាអតីតក្រុមប្រឹក្សាភិបាលនៃក្លឹបអ្នកវិនិយោគកម្ពុជា (Cambodia Investors Club)

២០១២-បច្ចុប្បន្ន
សមាជិក និងជាទីប្រឹក្សានៃ សភាពាណិជ្ជកម្មកម្ពុជា

២០១១-បច្ចុប្បន្ន
អភិបាលឯករាជ្យនៃ ធនាគារឯកទេស អ៊ីអន (AEON Specialized Bank Plc.)

លោកស្រី ខៀវ មាលី

មុខតំណែង: អភិបាលឯករាជ្យ
ឆ្នាំកំណើត: ១៩៦៤
កម្រិតវប្បធម៌: បេក្ខជនអនុបណ្ឌិតនៃនីតិពាណិជ្ជកម្មឯកជន នៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយសហការជាមួយ University of Bruxelle (ULB), University of Paris 8. បរិញ្ញាបត្រផ្នែកច្បាប់សាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

២០១៧-បច្ចុប្បន្ន
សមាជិកនៃ APAA និង APAA Group

២០១៦-បច្ចុប្បន្ន
សមាជិកនៃ ASEAN IPA Cambodia Group

២០១៤-បច្ចុប្បន្ន
អភិបាលឯករាជ្យនៃ AEON Specialized Bank(Cambodia) PLC.

២០១៤-បច្ចុប្បន្ន
សមាជិកក្រុមប្រឹក្សាភិបាលនៃ Nokor Tep WomenCancer Hospital

២០១៣-បច្ចុប្បន្ន
សមាជិកស្ថាបនិកនៃមជ្ឈមណ្ឌលជាតិមជ្ឈត្តិការពាណិជ្ជកម្ម

២០១០-បច្ចុប្បន្ន
សហប្រធាននៃ ការិយាល័យ SokSiphana & associates,a member of ZICOLAW

២០០៩-បច្ចុប្បន្ន
ភ្នាក់ងារម៉ាកពាណិជ្ជកម្ម

២០០៩-បច្ចុប្បន្ន
សមាជិកស្ថាបនិកនៃ Intellectual Property Associationof Cambodia

២០០៤-បច្ចុប្បន្ន
សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ឯកឧត្តមបណ្ឌិត សុក ស៊ីជាន់ណា

មុខតំណែង: ទីប្រឹក្សា
ឆ្នាំកំណើត: ១៩៦០
កម្រិតវប្បធម៌: បណ្ឌិតច្បាប់ (J.D) មហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យ Widener, Delaware (សហរដ្ឋអាមេរិក) សញ្ញបត្របណ្ឌិត (Ph.D) មហាវិទ្យាល័យ Bond Queensland (អូស្ត្រាលី)។ នាពេលបច្ចុប្បន្នកំពុងបន្តថ្នាក់បណ្ឌិតនៃសាកលវិទ្យាល័យ Paris 2, Pantheon-Assass ។

២០០៩-បច្ចុប្បន្ន
សាស្ត្រាចារ្យផ្នែកច្បាប់ និងគោលនយោបាយនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាលាភូមិន្ទរដ្ឋបាល។

២០០៩-បច្ចុប្បន្ន
ប្រធានការិយាល័យមេធាវីសុកស៊ីជាន់ណា និង សហការី ជាសមាជិកនៃ ZICO Law.

២០០៩-បច្ចុប្បន្ន
សាស្ត្រាចារ្យផ្នែកច្បាប់ និងគោលនយោបាយនៃសាកលវិទ្យាល័យ សាលាភូមិន្ទរដ្ឋបាល និងវិទ្យាស្ថានហិរញ្ញវត្ថុកម្ពុជា។

២០១៤-បច្ចុប្បន្ន
ទីប្រឹក្សានៃ AEON Specialize Bank (Cambodia) Plc.

តារាងរចនាសម្ព័ន្ធចាត់តាំង



ប្រវត្តិអាជីវកម្ម

2011

វិច្ឆិកា ទទួលបានអាជ្ញាប័ណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
ធ្នូ ដាក់ឲ្យដំណើរការសេវាកម្មបង់រំលស់

2014

មីនា ដាក់ឲ្យដំណើរកម្ចីផ្ទាល់ខ្លួន
ឧសភា បើកសម្ពោធសាខាខេត្តបាត់ដំបង
ឧសភា ផ្លាស់ប្តូរអាសយដ្ឋានទីស្នាក់ការកណ្តាល
មិថុនា បើកសម្ពោធសាខាផ្សារទំនើប អ៊ីអនម៉ល ភ្នំពេញ
មិថុនា ចាប់ផ្តើមសេវាប័ណ្ណសន្សំពន្ធសម្រាប់ អ៊ីអន ភ្នំពេញ
កញ្ញា ចាប់ផ្តើមការសងប្រាក់តាមរដូវកាលសម្រាប់សេវាកម្មបង់រំលស់គ្រឿងយន្តកសិកម្ម
តុលា បើកសម្ពោធសាខាខេត្តកំពង់ចាម

2016

កុម្ភៈ កម្លាយខ្លួនទៅជាធនាគារឯកទេស
មេសា កែលំអសាខាផ្សារទំនើប អ៊ីអនម៉ល
មេសា ចាប់ផ្តើមផ្តល់កាតអ៊ីអន ព័ណ៌មាស
កក្កដា ចាប់ផ្តើមផ្តល់កាតអ៊ីអន ព័ណ៌ស្វាយ

2012

មករា ដាក់ឲ្យដំណើរការសាវាកម្មបង់រំលស់សម្រាប់ទូរស័ព្ទដៃ
កក្កដា ដាក់ឲ្យដំណើរការសាវាកម្មបង់រំលស់សម្រាប់ម៉ូតូ

2013

មេសា ទទួលបានជាវិជ្ជមាននូវប្រាក់ចំណូលប្រចាំខែ
ឧសភា ដាក់ឲ្យដំណើរការសេវាកម្មបង់រំលស់សម្រាប់គ្រឿងយន្តកសិកម្ម
មិថុនា បើកសម្ពោធសាខាខេត្តសៀមរាប
កញ្ញា ដាក់ឲ្យដំណើរការកាតសមាជិក
ធ្នូ បើកសម្ពោធសាខាខណ្ឌចំការមន

2015

មីនា ចាប់ផ្តើមការធានារ៉ាប់រងលើសេវាកម្មបង់រំលស់ជាមួយក្រុមហ៊ុន Forte
តុលា ទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារឯកទេស
វិច្ឆិកា ដាក់ឲ្យដំណើរការពាក្យស្នើសុំតាមប្រព័ន្ធ Online

2017

មករា បើកសម្ពោធសាខាពោធិចិនតុង
កក្កដា ទីស្នាក់ការកណ្តាល និងផ្លាស់ប្តូរអាស័យដ្ឋានសាខាខេត្តបាត់ដំបង
សីហា កែលំអការិយាល័យកណ្តាល
តុលា កែលំអ និងផ្លាស់ប្តូរអាស័យដ្ឋានសាខាខេត្តសៀមរាម
ធ្នូ ទទួលបានពានរង្វាន់ពី VISA

AEON CARD
នេះគឺជាអ្វីដែលអ្នកត្រូវការ

សង្ខេបព័ត៌មានអាជីវកម្មសំខាន់ៗឆ្នាំ២០១៧

ពង្រីកអាជីវកម្មប័ណ្ណឥណទាន

ធនាគារឯកទេសអ៊ីអន ពង្រីកដែនអាជីវកម្មសេវាប័ណ្ណអ៊ីអន ទៅការសាខានៅតាមបណ្តាលខេត្តចំនួន ៣ បន្ថែមទៀតរួមមានសាខាខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តកំពង់ចាម ដើម្បីចេញប័ណ្ណឥណទានជូនអតិថិជនបង់រំលស់ និងដៃគូសហការណ៍អាជីវកម្មរបស់យើង។ ដោយខិតខំប្រឹងប្រែងផ្តល់ប័ណ្ណឥណទានជូនអតិថិជនធនាគារឯកទេសអ៊ីអនបានសម្រេចចេញប័ណ្ណឥណទានចំនួន ២១.៥០៩ ប័ណ្ណក្នុងឆ្នាំ ២០១៧ ដែលជាគ្រឹះស្ថានឈានមុខគេក្នុងការផ្តល់ប័ណ្ណឥណទានជូនអតិថិជនក្នុងប្រទេសកម្ពុជា។ កម្មវិធីសន្សំពន្ទុ Happy Plus Point Program គឺជាចំនុចខ្លាំងរបស់យើងក្នុងការធ្វើឲ្យអតិថិជនទទួលបាននូវអត្ថប្រយោជន៍ជាច្រើនជាមួយនឹងការចំណាយប្រាក់សម្រាប់ទិញទំនិញ ឬ សេវាផ្សេងៗនៅតាមហាងនានាក្នុងផ្សារទំនើបអ៊ីអនម៉ល់ ភ្នំពេញ។ ជាមួយគ្នានេះអតិថិជនទទួលបានអត្ថប្រយោជន៍ជាមួយដៃគូសហការណ៍ល្បីៗឈ្មោះរបស់យើងខ្ញុំចំនួន ១១៩ ដែលក្នុងនោះហាងចំនួន ៣៦៥ បានផ្តល់ការបញ្ចុះតម្លៃរហូតដល់ ៥០% ជូនអតិថិជនជាម្ចាស់ប័ណ្ណអ៊ីអន។ ដើម្បីផ្តល់នូវសេវាហិរញ្ញវត្ថុដែលភាពងាយស្រួល និងឆ្លើយតបនឹងតម្រូវការរបស់អតិថិជន និងដៃគូសហការយើងនឹងនៅតែបន្តអភិវឌ្ឍន៍ឲ្យមានអត្ថប្រយោជន៍បន្ថែមទៀតចំពោះប័ណ្ណអ៊ីអន ដើម្បីធ្វើឲ្យវាក្លាយទៅជាការប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់អតិថិជន។ ជាលទ្ធផលការលក់ប័ណ្ណឥណទានមានទំហំទឹកប្រាក់ចំនួន ១៦,២៧២ លានដុល្លារអាមេរិក។

ESTABLISHMENT OF E-MONEY BUSINESS

ទូទាត់ទំនិញជាមួយ
ÆON Wallet
Cambodia

Welcome to AEON Wallet App

Truly Experienced Cashless Payment Technology

ជំហានបន្ទាប់របស់ ធនាគារឯកទេស អ៊ីអន នឹងបន្តដើរតាមបាវចនារបស់ក្រុមហ៊ុន “រហ័ស សាមញ្ញ និង ងាយស្រួល” ដែល ធនាគារឯកទេស អ៊ីអន នឹងធ្វើការណែនាំផលិតផលថ្មី គឺ “អ៊ីអន វ៉លឡេត ខេមបូឌា” ទៅកាន់ទីផ្សារកម្ពុជា ដែលជាសេវាកម្មប្រកបដោយសុវត្ថិភាព និងភាពងាយស្រួលបំផុតក្នុងការនាំអតិថិជន និងអាជីវករខិតជិតទៅកាន់ពិភពឌីជីថល។

ធនាគារឯកទេស អ៊ីអន កំពុងតែលើកទឹកចិត្តឱ្យប្រើប្រាស់រូបិយវត្ថុប្រាក់រៀលដូច្នេះ អ៊ីអន វ៉លឡេត ខេមបូឌា ជាមូលដ្ឋានគ្រឹះសម្រាប់ប្រាក់រៀល។ បច្ចុប្បន្ននៃការប្រើរូបិយប្រាក់រៀលនឹងត្រូវបានគាំទ្រដោយអ៊ីអន វ៉លឡេត ខេមបូឌា របស់យើង។

ឥណទានលើរថយន្ត

ការប្រើប្រាស់យានជំនិះផ្ទាល់ខ្លួននៅតែជាតម្រូវការចាំបាច់សម្រាប់ប្រជាជនកម្ពុជា ដោយហេតុតែ ប្រព័ន្ធ ដឹកជញ្ជូនសាធារណៈ ស្ថិតនៅក្នុងដំណាក់កាលកំពុងអភិវឌ្ឍន៍នៅឡើយ។ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ អតិថិជន យើងមានគម្រោងដាក់ឲ្យដំណើរការសេវាបង់រំលស់រថយន្តនៅត្រីមាសទី២ ឆ្នាំ២០១៨។ សេវាកម្មបង់រំលស់នេះ ជាផ្នែកមួយនៃទីសដៅរបស់យើងក្នុងការសម្រួលដល់ការលើកកម្ពស់របៀបរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា។ ហេតុដូចនេះ លក្ខខណ្ឌក្នុងការស្នើសុំសេវាកម្មបង់រំលស់រថយន្តមានភាពងាយស្រួលបូករួមទាំងការចំណាយដ៏សមរម្យសម្រាប់ប្រជាជនទូទៅ។ សេវាកម្មបង់រំលស់រថយន្ត ចាប់ផ្តើមដាក់ឲ្យដំណើរការដំបូងនៅរាជធានីភ្នំពេញ និងធ្វើការពង្រីកប្រតិបត្តិការនេះនៅតាមបណ្តាខេត្តនានា នៅត្រីមាសទី៣ ឆ្នាំ២០១៨។

អ្នកណាក៏អាច មានរថយន្ត ផ្ទាល់ខ្លួនបានដែរ

ជាមួយសេវាកម្មបង់រំលស់ អ៊ីអន

- ឯកសារតម្រូវងាយស្រួល
- អនុម័តឥណទានរហ័ស

ការគ្រប់គ្រងផ្ទៃក្នុង

អនុលោមភាពរបស់ក្រុមហ៊ុន

យើងយល់ថាការអនុវត្តនៅក្នុងវិស័យហិរញ្ញវត្ថុអនុលោមភាពបានដើរតួរនាទីយ៉ាងសំខាន់ សម្រាប់កាលជោគជ័យនៃស្ថាប័នមួយ។ នៅធនាគារឯកទេស អ៊ីអន អនុលោមភាពផ្ទៃក្នុងនៃបុគ្គលិករបស់យើងត្រូវបានត្រួតពិនិត្យជាទៀងទាត់។

យើងផ្តោតលើ ការការពារព័ត៌មានបុគ្គល ក្រមសីលធម៌ និងបញ្ហាអនុលោមភាពផ្សេងៗទៀតដែលមានសារៈសំខាន់សម្រាប់ស្តង់ដារអន្តរជាតិនៃធនាគារមួយ។

ក្រៅពីនេះ ក្រុមការងារផ្ទៃកិច្ចការច្បាប់ និងភាពអនុលោមក៏យកចិត្តទុកដាក់យ៉ាងខ្លាំង ចំពោះអភិបាលកិច្ចសារជីវកម្មជាមួយនឹងបទបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជាដើម្បីធានាថាយើងបានអនុវត្តយ៉ាងពេញលេញស្របច្បាប់ និងយើងបានប្រើប្រាស់ភ្នាក់ងារខាងក្រៅផងដែរដើម្បីធានាបានពីប្រសិទ្ធិភាព។ ដើម្បីសម្រេចបានកិច្ចការនេះយើងបានបង្កើតអោយមាននូវ កម្មវិធីទំនើបសម័យកម្មច្បាប់ប្រចាំខែដែលតែងតែត្រួតពិនិត្យរាល់ការប្រែប្រួលនៃច្បាប់និងបទបញ្ញត្តិផ្សេងៗហើយរៀបចំខ្លួនសម្រាប់រាល់គ្រប់ការផ្លាស់ប្តូរដែលតម្រូវដោយច្បាប់។

ដោយឈរលើគោលការណ៍នៃការត្រួតពិនិត្យការអនុវត្តក៏ដូចជា ការប្រែប្រួលនៃច្បាប់ការធ្វើទំនើបកម្មតែងតែត្រូវបានធ្វើជាប្រចាំ។ ដើម្បីអោយមានភាពសមស្របទៅតាមប្រតិបត្តិការណ៍បច្ចុប្បន្ន និងការវិវឌ្ឍន៍នៃអាជីវកម្មយើងបានកែប្រែគោលនយោបាយផ្ទៃក្នុងជាច្រើន។ យើងក៏បានបង្កើតផងដែរនូវប្រតិទិនសារជីវកម្មដែលកត់ត្រារាល់របាយការណ៍ចាំបាច់ទាំងអស់ដើម្បីរាយការណ៍ទៅកាន់អាជ្ញាធរពាក់ព័ន្ធ ហើយយើងបានប្រើប្រាស់ប្រតិទិននេះដើម្បីពិនិត្យការអនុវត្តយ៉ាងពេញលេញនៃប្រព័ន្ធអនុលោមភាព។ ការបណ្តុះបណ្តាលសិក្ខាសាលាត្រូវបានអនុវត្តដើម្បីអាចអោយបុគ្គលិករបស់យើងអាចតាមទាន់ស្ថានភាពបច្ចុប្បន្ននៃប្រទេសកម្ពុជាដោយប្រើប្រាស់ការបណ្តុះបណ្តាលស្តីពីអនុលោមភាពប្រចាំឆ្នាំដែលនឹងបង្ហាត់ដល់បុគ្គលិកទាំងអស់រាល់ឆ្នាំហើយដើម្បីអោយពួកគេអាចដឹងពីការផ្លាស់ប្តូរ ដើម្បីចូលរួមក្នុងការពង្រឹងអនុលោមភាពទាំងអស់គ្នា។

យើងក៏ធ្វើអោយកាន់តែប្រសើរឡើងនូវការប្រឆាំងការសម្អាតប្រាក់តាមរយៈការបង្កើតការគ្រប់គ្រងការប្រឆាំងការសម្អាតប្រាក់ ការត្រួតពិនិត្យសាវតាជាតិរបស់អិចិជន ការពិនិត្យឈ្មោះអតិថិជននិងយន្តការនៃការរាយការណ៍រួមទាំងការបណ្តុះបណ្តាលពីការប្រឆាំងការសម្អាតប្រាក់ផងដែរ។

ការគ្រប់គ្រងហានិភ័យ

ក្រុមហ៊ុនចាត់ទុកការគ្រប់គ្រងហានិភ័យជាធាតុសំខាន់មួយនៃអាជីវកម្ម និងបង្កប់វប្បធម៌ហានិភ័យរឹងមាំ នៅក្នុងប្រតិបត្តិការអាជីវកម្មពីមួយថ្ងៃទៅមួយថ្ងៃ។ ដោយយល់ច្បាស់អំពីសារៈសំខាន់នៃការគ្រប់គ្រងហានិភ័យសម្រាប់កំណើនប្រកបដោយចីរភាព ក្រុមការងារគ្រប់គ្រងហានិភ័យបានចូលរួមក្នុងដំណាក់កាលដំណើរការគ្រប់គ្រងហានិភ័យដើម្បីផ្តល់នូវគំនិត និងទស្សនៈដោយឯករាជ្យ ដូចជាការត្រួតពិនិត្យការរៀបចំផែនការ និងការដឹកនាំការគ្រប់គ្រងហានិភ័យរបស់ខ្លួនផ្ទាល់។ ក្រុមហ៊ុនបានរៀបចំអោយមាននូវកិច្ចប្រជុំការគ្រប់គ្រងហានិភ័យថ្នាក់តំបន់ប្រចាំខែដែលមានសមាភាពចូលរួមពីប្រទេសជប៉ុន ថៃ មីយ៉ាមា និងឡាវ ដែលសុទ្ធសឹងជាក្រុមហ៊ុនសម្ព័ន្ធ នៃអ៊ីអនគ្រុប ក្នុងតំបន់មេគង្គ ដើម្បីត្រួតពិនិត្យលើហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យសន្ទនីយភាព និងហានិភ័យប្រតិបត្តិការ។

គណៈកម្មការគ្រប់គ្រងហានិភ័យ (“គគហ”) ត្រូវបានដឹកនាំដោយអភិបាលឯករាជ្យហើយផ្តោតលើការធ្វើការសិក្សាបែបស៊ីជម្រៅការពិភាក្សា និងចែករំលែកព័ត៌មានជាមួយបណ្តាក្រុមហ៊ុននៅបរទេសដូចជាទីស្នាក់ការកណ្តាលនៅប្រទេសថៃនិងជប៉ុនដើម្បីកែលំអនិងជម្នះលើការអនុវត្តការគ្រប់គ្រងហានិភ័យ។ គណៈកម្មការនេះជួបប្រជុំជារៀងរាល់ខែដើម្បីធានាថាយើងខ្ញុំធ្វើប្រតិបត្តិការដោយមានប្រព័ន្ធគ្រប់គ្រងហានិភ័យដែលមានភាពរឹងមាំ ប្រសិទ្ធិផល ប្រសិទ្ធិភាព។

ទំនួលខុសត្រូវផ្នែកសង្គមរបស់ក្រុមហ៊ុន

ក្នុងនាមសហគ្រាសមួយដែលប្រកបអាជីវកម្មនៅកម្ពុជា ក្រុមហ៊ុនដឹងច្បាស់ពីសារៈសំខាន់នៃបេសកកម្មរបស់យើង ក្នុងការបម្រើជាក្រុមហ៊ុននាំមុខគេនៅក្នុងចំណែកនៃសេដ្ឋកិច្ច ក៏ដូចជាទំនួលខុសត្រូវផ្នែកសង្គមរបស់យើងផងដែរ។ ក្រុមហ៊ុនបាននឹងកំពុងផ្តល់អាហារូបករណ៍ដល់និស្សិតសាកលវិទ្យាល័យ ដាំដើមឈើ និងជីកអណ្តូងទឹក ជាមួយក្រុមហ៊ុនទាំងឡាយនៃអ៊ីអនគ្រុប។ ឆ្នាំ ២០១៧ យើងផ្តោតលើការគាំទ្របរិស្ថានបៃតងស្អាតជាមួយនឹងគំនិតច្នៃប្រឌិតដែលបន្តឥតឈប់ឈរជាប្រចាំតាំពីឆ្នាំ ២០១៦។ យើងបានកំពុងចាប់ផ្តើមសកម្មភាពទីក្រុងស្អាតជាមួយបុគ្គលិកប្រមាណ ៣៨០ នាក់នៅតំបន់ភ្នំពេញ និងតាមសាខាខេត្តទាំងអស់ដោយទទួលបានកិច្ចសហការពីក្រសួងទេសចរណ៍។ នៅឆ្នាំ ២០១៧យើងក៏បានចាប់ផ្តើមកែច្នៃផលិតផលឡើងវិញដូចជាដបប្លាស្ទិក កំប៉ុងក្រដាសនិងសំបកកេះជាដើមនៅទីស្នាក់កណ្តាល ទីក្រុងភ្នំពេញក្នុងគោលបំណងអប់រំបុគ្គលិកផ្នែកក្នុងអោយយល់ច្បាស់ពីបរិស្ថាននិងផ្តល់ផលប្រយោជន៍ដល់សង្គមផងដែរ។ យោងទៅតាមរយៈសកម្មភាពទាំងអស់ នេះយើងខ្ញុំនឹងធ្វើការស្វែងរកមធ្យោបាយល្អប្រសើរជាងនេះ ក្នុងការរួមចំណែកដល់សង្គមកម្ពុជានិងពង្រឹងនូវភាពអាចទុកចិត្តបាន។ ទំនួលខុសត្រូវផ្នែកសង្គមរបស់សហគ្រាសមិនមែនជារឿងសាមញ្ញទេនៅប្រទេសកម្ពុជា ឬមានតែមនុស្សមួយចំនួនតូចដែលដឹងច្បាស់ពីសារៈសំខាន់នៃវាដូចច្នេះហើយវិធី នៃទំនួលខុសត្រូវ ផ្នែកសង្គមរបស់សហគ្រាសគឺផ្តោតទៅលើឱកាសដែលយើងអាចធ្វើការងារជាបន្តបន្ទាប់និងជាប្រចាំ។

របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិក ធនាគារឯកទេស អឺអន (ខេមបូឌា) ភីអិលស៊ី

មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារឯកទេស អ៊ឺអន (ខេមបូឌា) ភីអិលស៊ី (ហៅកាត់ថា "ធនាគារ") ដែលរួមមានតារាងតុល្យការនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017 របាយការណ៍លទ្ធផល របាយការណ៍ស្តីពី បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀត ដែលបានបង្ហាញ នៅទំព័រទី 16 ដល់ 42។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពត្រឹមត្រូវជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនា ថ្ងៃទី 31ខែ ធ្នូ ឆ្នាំ 2017 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុនិងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងបទប្បញ្ញត្តិ និងគោលការណ៍ណែនាំទាក់ទងទៅនឹងគណនេយ្យ របស់ធនាគារជាតិនៃកម្ពុជា។

មូលដ្ឋានសំរាប់មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ដោយអនុលោមទៅតាមស្តង់ដារទាំងនេះគឺត្រូវបានរៀបរាប់នៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុនៃរបាយការណ៍នេះ។ យើងខ្ញុំឯករាជ្យពីធនាគារដោយអនុលោមទៅតាមការតម្រូវក្រមសីលធម៌ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុនៅប្រទេសកម្ពុជាព្រមទាំងបានបំពេញនូវការទទួលខុសត្រូវលើក្រមសីលធម៌ផ្សេងៗទៀតដោយអនុលោមទៅតាមការតម្រូវទាំងនេះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងបានទទួលគឺគ្រប់គ្រាន់ និង សមរម្យដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ការផ្តល់មតិរបស់យើងខ្ញុំ។

បញ្ហាផ្សេង។

សវនករផ្សេងទៀតបានធ្វើសវនកម្ម លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ សំរាប់ដំណាច់ឆ្នាំ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 ដោយបានបង្ហាញនូវមតិសវនកម្ម ដែលមិនមានការកែតម្រូវលើរបាយការណ៍ហិរញ្ញវត្ថុនោះទេ នាថ្ងៃទី 6 ខែ មីនា ឆ្នាំ 2017 ។

ព័ត៌មានផ្សេង។ក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលបានទទួលត្រឹមកាលបរិច្ឆេទ នៃរបាយការណ៍សវនកម្មនេះគឺរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារដែលរំពឹងថារួចរាល់បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។

មតិយោបល់របស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុមិនគ្របដណ្តប់ព័ត៌មានផ្សេងៗ ហើយយើងខ្ញុំមិនធ្វើការសន្និដ្ឋានអះអាងលើព័ត៌មានផ្សេងៗឡើយ។

ទាក់ទងទៅនឹងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុការទទួលខុសត្រូវរបស់យើងខ្ញុំគឺអានព័ត៌មានផ្សេងៗ និងពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានឬមិនមានភាពស្របគ្នាជាមួយរបាយការណ៍ហិរញ្ញវត្ថុជាសារវន្ត ឬ ជាមួយចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្ម ឬ មានកំហុសឆ្គងជាសារវន្ត។ ប្រសិនបើផ្អែកទៅលើការងាររបស់យើងខ្ញុំដែលបានអនុវត្ត ហើយសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើព័ត៌មានផ្សេងៗ យើងខ្ញុំនឹងធ្វើការរាយការណ៍ទៅលើភាពជាក់ស្តែងនោះយើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ឡើយ។

ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលសំរាប់របាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវលើការរៀបចំ និងបង្ហាញភាពត្រឹមត្រូវលើរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងបទប្បញ្ញត្តិ និងគោលការណ៍ណែនាំទាក់ទងទៅនឹងគណនេយ្យរបស់ធនាគារជាតិនៃកម្ពុជានិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការប៉ាន់ប្រមាណពីលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការបង្ហាញ បញ្ហាដែលពាក់ព័ន្ធនឹងការបន្តនិរន្តរភាពប្រសិនបើមាន និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពគណនេយ្យ លើកលែងតែគណៈគ្រប់គ្រងមានបំណងរំលាយធនាគារ ឬបញ្ឈប់អាជីវកម្ម ឬ មិនមានជម្រើសជាក់ស្តែងណាមួយក្រៅពីអនុវត្តដូច្នេះ។

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវលើការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបានអំណះអំណាងដែលសមហេតុផលថា តើរបាយការណ៍ហិរញ្ញវត្ថុជារួម គឺមិនមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ កំហុសឆ្គង និងដើម្បីបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលរួមបញ្ចូលមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងដែលសមហេតុផល គឺជាអំណះអំណាងកំរិតខ្ពស់ ប៉ុន្តែមិនមែនជាការធានាថា ការធ្វើសវនកម្មអនុលោមតាមស្តង់ដារ សវនកម្មអន្តរជាតិនៃកម្ពុជា នឹងតែងតែរកឃើញកំហុសឆ្គងជាសារវន្តនៅពេលដែលវាមាននោះទេ កំហុសឆ្គងនេះអាចកើតឡើងពីការក្លែងបន្លំ ឬ កំហុសឆ្គង ហើយត្រូវបានពិចារណាជាកំហុសឆ្គងជាសារវន្ត ប្រសិនបើកំហុសនិមួយៗ ឬ កំហុសរួមមានឥទ្ធិពលដល់ការសម្រេចចិត្តសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងបានធ្វើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណតាមវិជ្ជាជីវៈយើងខ្ញុំក៏បានៈ

- កំណត់និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ទោះជាបណ្តាលមកពីការក្លែងបន្លំ ឬ កំហុសឆ្គងក៏ដោយ កំណត់ និងអនុវត្តនិតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះដើម្បីទទួលបានភស្តុតាងពីការធ្វើសវនកម្មដែលគ្រប់គ្រាន់ និងសមរម្យដើម្បីផ្តល់ជាមូលដ្ឋានក្នុងការផ្តល់មតិយោបល់។ ហានិភ័យដែលមិនបានរកឃើញកំហុសឆ្គងជាសារវន្តពីការក្លែងបន្លំគឺធ្ងន់ធ្ងរជាងកំហុសឆ្គងធម្មតាខណៈដែលការក្លែងបន្លំអាចបណ្តាលមកពីការឃុបឃិតការក្លែងការលុបចោល ដោយចេតនា ការរាយការណ៍ខុសពីការពិត ឬ ការបំពានលើការគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបាន ការយល់ដឹងពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ដើម្បីរៀបចំនិតិវិធីសវនកម្មដែលសមរម្យទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសំរាប់គោលបំណងបញ្ចេញមតិទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារឡើយ។
- វាយតម្លៃភាពត្រឹមត្រូវនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ភាពសមហេតុផលនៃការប៉ាន់ស្មាន គណនេយ្យ និងការបង្ហាញដែលពាក់ព័ន្ធនានាដោយគណៈគ្រប់គ្រង។
- សន្និដ្ឋានភាពសមហេតុផល មូលដ្ឋាននៃការប្រើប្រាស់គោលការណ៍គណនេយ្យនិរន្តរភាព នៃដំណើរការអាជីវកម្មរបស់គណៈគ្រប់គ្រង និងផ្អែកទៅលើភស្តុតាងសវនកម្មដែលបានទទួលថាតើភាពមិនប្រាកដជាសារវន្តកើតមានឡើងដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ឬ លក្ខខណ្ឌដែលអាចមានភាពមិនច្បាស់លាស់ទៅលើលទ្ធភាពរបស់ធនគារដើម្បីបន្តនិរន្តរភាពនៃដំណើរការអាជីវកម្មទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានភាពមិនប្រាកដប្រជាជាសារវន្តយើងខ្ញុំត្រូវអោយមានការទាញចំណាប់អារម្មណ៍នៅក្នុងរបាយការណ៍របស់សវនករ ទៅលើការបង្ហាញដែលពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឬប្រសិនបើការបង្ហាញមិនគ្រប់គ្រាន់ យើងខ្ញុំត្រូវបញ្ជាក់នៅក្នុងមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់ថ្ងៃនៃរបាយការណ៍សវនកម្ម។ ទោះជាយ៉ាងណាព្រឹត្តិការណ៍ឬលក្ខខណ្ឌនាពេលអនាគតអាចបណ្តាលអោយធនាគារបញ្ឈប់ការបន្តនិរន្តរភាពនៃដំណើរការអាជីវកម្ម។
- វាយតម្លៃការបង្ហាញជារួម រចនាសម្ព័ន្ធ និង ខ្លឹមសារ នៃរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការបង្ហាញ ថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញប្រតិបត្តិការជាមូលដ្ឋាននិងព្រឹត្តិការណ៍នៅក្នុងការទទួលបានការបង្ហាញដែលត្រឹមត្រូវ។

យើងខ្ញុំទាក់ទងជាមួយក្រុមប្រឹក្សាភិបាល ពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងៗ ដូចជាវិសាលភាព និងពេលវេលានៃការធ្វើសវនកម្មនិងការរកឃើញពីសវនកម្មសំខាន់ៗ រួមទាំងកង្វះខាតសំខាន់ៗនៃការត្រួតពិនិត្យផ្ទៃក្នុងដែលបានរកឃើញនៅក្នុងអំឡុងពេលធ្វើសវនកម្មរបស់យើងខ្ញុំ។

តំណាងក្រុមហ៊ុន ឌីឡយ៍ធ៍ (ខេមបូឌា) ខូ អិលធីឌី

Khoy Kimleng
Director

តារាងតុល្យការ

នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017

		ឆ្នាំ 2017		ឆ្នាំ 2016	
	កំណត់សម្គាល់	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្ម					
សាច់ប្រាក់ក្នុងដៃ	4	242,884	980,523	185,874	750,373
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	5	637,384	2,573,119	522,343	2,108,699
សមតុល្យនៅធនាគារនានា	6	2,116,532	8,544,440	1,484,889	5,994,497
ឥណទានផ្តល់ដល់អតិថិជន	7	35,956,288	145,155,535	33,357,226	134,663,120
ទ្រព្យសកម្មផ្សេងៗ	8	2,322,233	9,374,855	1,778,964	7,181,678
ទ្រព្យ និងបរិក្ខារ	9	2,217,176	8,950,740	1,191,127	4,808,580
ទ្រព្យសកម្មអរូបី	10	2,190,843	8,844,433	2,289,594	9,243,091
ទ្រព្យសកម្មពន្ធពន្យារ	12(ក)	245,893	992,670	200,776	810,533
ទ្រព្យសកម្មសរុប		**45,929,233**	**185,416,315**	**41,010,793**	**165,560,571**
បំណុល និងមូលធន					
បំណុលផ្សេងៗ	11	1,519,019	6,132,280	992,029	4,004,821
គណនីត្រូវទូទាត់សងសម្ព័ន្ធញាតិ	22(ក)	42,783	172,715	115,836	467,630
បំណុលពន្ធលើប្រាក់ចំណេញ	12(ខ)	17,481	70,571	139,195	561,930
ប្រាក់កម្ចី	13	30,700,000	123,935,900	28,690,000	115,821,530
បំណុលសរុប		**32,279,283**	**130,311,466**	**29,937,060**	**120,855,911**
មូលធន					
ដើមទុន	14	12,500,000	50,462,500	10,000,000	40,370,000
ប្រាក់ចំណេញរក្សាទុក		1,149,950	4,642,349	1,073,733	4,334,660
សរុបមូលធន		**13,649,950**	**55,104,849**	**11,073,733**	**44,704,660**
បំណុល និងមូលធនសរុប		**45,929,233**	**185,416,315**	**41,010,793**	**165,560,571**

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយពីទំព័រទី 19 ដល់ទី 42 គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

របាយការណ៍លទ្ធផល

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017

		ឆ្នាំ 2017		ឆ្នាំ 2016	
	កំណត់សម្គាល់	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណូលពីការប្រាក់	15	9,517,710	38,422,995	8,490,942	34,277,933
ចំណាយលើការប្រាក់	13	(686,891)	(2,772,979)	(455,710)	(1,839,701)
ចំណូលសុទ្ធពីការប្រាក់		**8,830,819**	**35,650,016**	**8,035,232**	**32,438,232**
ចំណូលកម្រៃជើងសានិងផ្សេងៗ	16	840,115	3,391,544	527,837	2,130,878
ចំណេញប្រតិបត្តិការ		**9,670,934**	**39,041,560**	**8,563,069**	**34,569,110**
វិធានធនលើឥណទានអាក្រក់និងជាប់សង្ស័យ	7	(1,406,989)	(5,680,015)	(1,271,981)	(5,134,987)
ចំណាយលើបុគ្គលិក	17	(3,432,324)	(13,856,292)	(2,857,842)	(11,537,108)
រំលស់	18	(1,317,110)	(5,317,173)	(1,315,937)	(5,312,438)
ចំណាយប្រតិបត្តិការផ្សេងៗ	19	(3,359,837)	(13,563,662)	(3,022,175)	(12,200,520)
ប្រាក់ចំណេញមុនបង់ពន្ធ		**154,674**	**624,418**	**95,134**	**384,057**
ចំណាយពន្ធលើប្រាក់ចំណេញ		**(78,457)**	**(316,731)**	**(78,377)**	**(316,408)**
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ		**76,217**	**307,687**	**16,757**	**67,649**

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយពីទំព័រទី 19 ដល់ទី 42 គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017

	ដើមទុន	ប្រាក់ចំណេញរក្សាទុក	សរុប
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
សមតុល្យនាថ្ងៃទី 1 **ខែ មករា ឆ្នាំ** 2016	10,000,000	1,056,976	11,056,976
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	16,757	16,757
សមតុល្យនាថ្ងៃទី 31 **ខែ ធ្នូ ឆ្នាំ** 2016	10,000,000	1,073,733	11,073,733
សមមូលនឹងពាន់រៀល នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	40,370,000	4,334,660	44,704,660
សមតុល្យនាថ្ងៃទី 1 **ខែ មករា ឆ្នាំ** 2017	10,000,000	1,073,733	11,073,733
មូលធនបោះផ្សាយក្នុងឆ្នាំ	2,500,000	-	2,500,000
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	76,217	76,217
សមតុល្យនាថ្ងៃទី 31 **ខែ ធ្នូ ឆ្នាំ** 2017	12,500,000	1,149,950	13,649,950
សមមូលនឹងពាន់រៀល នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	50,462,500	4,642,349	55,104,849

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយពីទំព័រទី 19 ដល់ទី 42 គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017

		ដំណាច់ឆ្នាំ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ដំណាច់ឆ្នាំ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	កំណត់សំគាល់	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ					
ប្រាក់ចំណេញមុនបង់ពន្ធ		154,674	624,418	95,134	384,056
វិធានធនលើឥណទាន					
អាក្រក់ និងជាប់សង្ស័យ	7	1,406,989	5,680,015	1,271,981	5,134,987
ចំណាយរំលស់	18	1,317,110	5,317,173	1,315,937	5,312,438
ខាតបង់លើការលុបចោលទ្រព្យ និងបរិក្ខារ	19	-	-	635	2,563
ចំណូលពីការប្រាក់សុទ្ធ		(8,830,819)	(35,650,016)	(8,035,232)	(32,438,232)
ការប្រែប្រួលទុនចល័ត:					
សមតុល្យនៅធនាគារជាតិ		(125,000)	(504,625)	-	-
ឥណទានផ្តល់ដល់អតិថិជន		(4,006,051)	(16,172,428)	(7,467,984)	(30,148,251)
ទ្រព្យសកម្មផ្សេងៗ		(450,820)	(1,819,959)	(218,145)	(880,651)
បំណុលផ្សេងៗ		367,356	1,483,017	230,233	929,451
បំណុលនៃភាគីពាក់ព័ន្ធ		(73,053)	(294,915)	(88,442)	(357,040)
សាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ		(10,239,614)	(41,337,320)	(12,895,883)	(52,060,679)
ការប្រាក់បានទទួល		9,425,261	38,049,779	8,386,093	33,854,657
ការប្រាក់បានបង់		(657,349)	(2,653,718)	(410,843)	(1,658,574)
ពន្ធលើប្រាក់ចំណេញបានបង់	12(ខ)	(245,288)	(990,228)	(368,459)	(1,487,469)
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ		**(1,716,990)**	**(6,931,487)**	**(5,289,092)**	**(21,352,065)**
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ					
ការទិញទ្រព្យ និងបរិក្ខារ		(1,564,043)	(6,314,042)	(526,648)	(2,126,078)
ការទិញទ្រព្យអរូបី	10	(550,273)	(2,221,452)	(282,648)	(1,141,050)
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ		**(2,114,316)**	**(8,535,494)**	**(809,296)**	**(3,267,128)**
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន					
សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី		22,700,000	91,639,900	13,000,000	52,481,000
ការទូទាត់សងប្រាក់កម្ចី		(20,690,000)	(83,525,530)	(6,200,000)	(25,029,400)
ភាគហ៊ុនបានបោះផ្សាយ		2,500,000	10,092,500	-	-
សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន		4,510,000	18,206,870	6,800,000	27,451,600
ការកើនឡើងសុទ្ធនូវសាច់ប្រាក់ និងសាច់ប្រាក់សមមូល		678,694	2,739,889	701,612	2,832,407
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ		1,693,106	6,835,069	991,494	4,015,551
លម្អៀងពីការប្តូររូបិ		-	-	-	(12,889)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ	**20**	**2,371,800**	**9,574,958**	**1,693,106**	**6,835,069**

ប្រតិបត្តិការមិនមែនជាសាច់ប្រាក់សំខាន់ៗ

* ក្នុងឆ្នាំ 2017 មានការដាក់បញ្ចូលនូវការទិញទ្រព្យ និងសម្ភារៈចំនួន 130,092 ដុល្លារអាមេរិកដែលពុំទាន់បង់ប្រាក់ដែលនៅក្នុងគណនីជំពាក់ទិញ-លក់ និងផ្សេងៗ (2016: ពុំមាន) ។

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយពីទំព័រ 19 ទៅ 42 គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

១ ព័ត៌មានអំពីធនាគារ

ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី (ហៅកាត់ថា"ធនាគារ") បានទទួលអាជ្ញាប័ណ្ណជាធនាគារឯកទេសដែលបានបង្កើតឡើងនិងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ធនាគារបានចុះបញ្ជី ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបង្កើតនៅក្នុងប្រទេសកម្ពុជានាថ្ងៃទី 5 ខែ តុលា ឆ្នាំ 2011 ក្រោមការចុះបញ្ជីការលេខ 00006388 ដែលចេញដោយក្រសួងពាណិជ្ជកម្ម។ ធនាគារទទួលបានអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី 21 ខែ វិច្ឆិកា ឆ្នាំ 2011 ។ ភាគហ៊ុនរបស់ធនាគារត្រូវបានកាន់កាប់ទាំងស្រុងដោយ ក្រុមហ៊ុន AEON Thana Sisap (Thailand) Public Company Limited ដែលជាក្រុមហ៊ុនដែលបានចុះបញ្ជីនៅប្រទេសថៃ។ ក្រុមហ៊ុនមេធំបំផុត គឺ AEON Co., Ltd. ដែលបានចុះបញ្ជីនៅប្រទេសជប៉ុន ។

នៅថ្ងៃទី 26 ខែ តុលា ឆ្នាំ 2015 ធនាគារទទួលបានអាជ្ញាប័ណ្ណជាធនាគារឯកទេសពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើប្រតិបត្តិការជាធនាគារឯកទេសដែលមានសុពលភាពជាអចិន្ត្រៃយ៍។ នាថ្ងៃទី 1 ខែ កុម្ភៈ ឆ្នាំ 2016 ធនាគារទទួលបានការអនុម័តពីក្រសួងពាណិជ្ជកម្មលើការផ្លាស់ប្តូរឈ្មោះពី អ៊ីអន ម៉ាយក្រូហ្វាយនែន (ខេមបូឌា) ទៅជា ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី និងផ្លាស់ប្តូរចន្លាសម្ព័ន្ធនៃការកាន់កាប់ភាគហ៊ុនទៅជា 80% កាន់កាប់ដោយ AEON Thana Sinsap (Thailand) Public Company Limited និង 20% កាន់កាប់ដោយ AEON Financial Co., Ltd ។

សកម្មភាពចម្បងរបស់ធនាគារមានដូចខាងក្រោម៖

- សេវាកម្មកាតឥណទាន
- សេវាកម្មផ្តល់ប្រាក់កម្ចីក្នុងទម្រង់ជាការទិញបណ្តាក់ (បង់រំលស់) និងឥណទាន
- សេវាកម្មពាក់ព័ន្ធដទៃទៀតដែលអនុម័តដោយធនាគារជាតិនៃកម្ពុជា។

ការិយាល័យរបស់ធនាគារស្ថិតនៅអគារ 721 មហាវិថីព្រះមុន្នីវង្ស សង្កាត់បឹងកេងកង 3 ខណ្ឌ ចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតអោយចេញផ្សព្វផ្សាយ ដោយក្រុមប្រឹក្សាភិបាល ថ្ងៃទី 26 ខែ កុម្ភៈ ឆ្នាំ 2018 ។

២ គោលការណ៍គណនេយ្យសំខាន់។

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានអនុម័តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម។ គោលការណ៍ទាំងនេះត្រូវបានគេអនុវត្តដូចៗគ្នាចំពោះគ្រប់ការិយបរិច្ឆេទទាំងអស់ ដែលបានបង្ហាញលើកលែងតែមានការចែងផ្ទុយពីនេះ។

២.១ មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលបានបង្ហាញជារូបិយប័ណ្ណដុល្លារអាមេរិក ត្រូវបានរៀបចំឡើងតាមសម្មតិកម្មតម្លៃដើមនិងអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជានិងបទបញ្ជត្តិនិងគោលការណ៍ណែនាំទាក់ទងនឹងគណនេយ្យរបស់ធនាគារជាតិនៃកម្ពុជា។ គោលការណ៍គណនេយ្យនេះមានលក្ខណៈខុសពីគោលការណ៍គណនេយ្យដែលទទួលស្គាល់ជាទូទៅ ដែលបានអនុវត្តនៅប្រទេសនិងដែនសមត្ថកិច្ចក្រៅពីប្រទេសកម្ពុជា។ របាយការណ៍ហិរញ្ញវត្ថុដែលមានភ្ជាប់ត្រូវបានរៀបចំឡើងដោយពុំមានគោលបំណងធ្វើការបង្ហាញពីស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលនៃប្រតិបត្តិការរបស់ធនាគារនិងស្ថានភាពចរន្តសាច់ប្រាក់របស់ធនាគារដោយអនុលោមទៅតាមគោលការណ៍គណនេយ្យដែលបានអនុវត្តនៅប្រទេស និងដែនសមត្ថកិច្ចក្រៅពីប្រទេសកម្ពុជានោះទេ។ ហេតុដូច្នេះ របាយការណ៍ហិរញ្ញវត្ថុនេះ គឺត្រូវបានធ្វើឡើងសំរាប់អ្នកដែលបានយល់ដឹងពីគោលការណ៍បទបញ្ជត្តិ និងការអនុវត្តគណនេយ្យកម្ពុជាប៉ុណ្ណោះ។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំដោយប្រើប្រាស់អាត្រាថ្លៃដើមដំបូង។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជានិងបទបញ្ជត្តិនិងគោលការណ៍ណែនាំទាកទងនឹងគណនេយ្យរបស់ធនាគារជាតិនៃកម្ពុជាតម្រូវអោយប្រើការប៉ាន់ប្រមាណនិងការសន្មតដោយសមហេតុផលដែលមានឥទ្ធិពលលើតួលេខដែលបានរាយការណ៍លើទ្រព្យសកម្មនិងបំណុលនិងការបង្ហាញនៃទ្រព្យសកម្ម និងបំណុលយថាហេតុនាកាលបរិច្ឆេទនៃរបាយការណ៍នេះនិងតួលេខដែលបានរាយការណ៍លើចំណូលនិងចំណាយនាការិយបរិច្ឆេទនៃរបាយការណ៍។ ទោះបីជាការប៉ាន់ប្រមាណទាំងនេះមានមូលដ្ឋានលើការយល់ដឹងរបស់គណៈគ្រប់គ្រងនូវព្រឹត្តិការណ៍និងសកម្មភាពបច្ចុប្បន្ន ប៉ុន្តែលទ្ធផលជាក់ស្តែងចុងក្រោយអាចមានភាពខុសគ្នាពីការប៉ាន់ប្រមាណទាំងនោះ។ ផ្នែកដែលពាក់ព័ន្ធនិងការវិនិច្ឆ័យកម្រិតខ្ពស់ ឬមានភាពស្មុគស្មាញ ឬការប៉ាន់ប្រមាណ និងការសន្មតដែលសំខាន់ចំពោះរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ទី 3។

២.២ ក្របខ័ណ្ឌនៃរបាយការណ៍ហិរញ្ញវត្ថុ

នៅថ្ងៃទី 28 ខែសីហា ឆ្នាំ 2009 ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញ សេចក្តីជូនដំណឹង ស្តីអំពីការដាក់អោយអនុវត្តនូវ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា “CIFRS”) ដែលផ្អែកលើ ស្តង់ដារដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យ អន្តរជាតិ (ហៅកាត់ថា “IASB”) ដោយរួមបញ្ចូលទាំងបំណកស្រាយ និងវិសោធនកម្មផ្សេងៗ ។ ស្ថាប័នដែលមានការទទួលខុសត្រូវជាសាធារណៈត្រូវតែរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយយោងតាមស្តង់ដារ CIFRS សម្រាប់ការិយបរិច្ឆេទចាប់ផ្តើមពីថ្ងៃទី 1 ខែ មករា ឆ្នាំ 2012 ឬបន្ទាប់ពីនេះ។

ក្រុមប្រឹក្សាជាតិគណនេយ្យ (ហៅកាត់ថា “NAC”) នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញ សារាចរណែនាំលេខ 086 MoEF.NAC ចុះថ្ងៃទី 30 ខែកក្កដា ឆ្នាំ 2012 ដោយអនុម័តអោយធនាគារ និង ស្ថាប័នហិរញ្ញវត្ថុពន្យារពេលការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញ វត្ថុអន្តរជាតិនៃកម្ពុជារហូតដល់ថ្ងៃទី 01 ខែ មករា ឆ្នាំ 2016។ នៅ ថ្ងៃទី 24 ខែ មីនា ឆ្នាំ 2016 ក្រុមប្រឹក្សាជាតិគណនេយ្យ បានចេញ សេចក្តីជូនដំណឹងលេខ 058 MoEF.NAC ដោយអនុញ្ញាតអោយ ធនាគារ និងស្ថាប័នហិរញ្ញវត្ថុពន្យារពេលការអនុវត្តស្តង់ដាររបាយការណ៍ ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា រហូតដល់ថ្ងៃទី 01 ខែមករា ឆ្នាំ 2019 ដោយ យោងទៅតាមសំណើរបស់ធនាគារជាតិនៃកម្ពុជាចុះថ្ងៃទី 16 ខែវិច្ឆិកា ឆ្នាំ 2015។

ស្តង់ដារគណនេយ្យបច្ចុប្បន្នត្រូវបានប្រើខុសពី ស្តង់ដារ CIFRS លើ ផ្នែកជាច្រើន។ ដូចនេះការអនុវត្តស្តង់ដារ CIFRS អាចមានផលប៉ះពាល់ យ៉ាងខ្លាំងទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។ អ្នកគ្រប់គ្រង កំពុងវាយតម្លៃផលប៉ះពាល់ពេញលេញនៃការផ្លាស់ប្តូរទៅនឹងក្រប ខណ្ឌស្តង់ដារ CIFRS ប៉ុន្តែមិនបានបញ្ចប់នៅឡើយទេគិតត្រឹមកាល បរិច្ឆេទនៃរបាយការណ៍នេះទេ។

២.៣ ប្រតិបត្តិការជាមួយរូបិយប័ណ្ណបរទេស

(ក) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់កំណត់បង្ហាញ

ធាតុទាំងអស់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានគិត ដោយប្រើប្រាស់រូបិយប័ណ្ណ នៃសេដ្ឋកិច្ចជាមូលដ្ឋានដែលធនាគារ ប្រតិបត្តិ(“រូបិយប័ណ្ណគោល”)។ គណៈគ្រប់គ្រងបានកំណត់ប្រាក់ដុល្លារ អាមេរិកជារូបិយប័ណ្ណគោលរបស់ធនាគារ ដោយសារតែប្រាក់ដុល្លារ អាមេរិកមានឥទ្ធិពលខ្លាំងលើប្រតិបត្តិការរបស់ធនាគារ។ របាយការណ៍ ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណគោល របស់ធនាគារ និងជារូបិយប័ណ្ណសម្រាប់កំណត់បង្ហាញ។

(ខ) ប្រតិបត្តិការ និង សមតុល្យ

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់ដុល្លារ អាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ នៅថ្ងៃប្រតិបត្តិការនោះ។ ការចំណេញ និងការខាតលើការប្តូររូបិយប័ណ្ណ គឺជាលទ្ធផលនៃការទូទាត់នៃប្រតិបត្តិការទាំងនោះ និងពីការបកប្រែ ទ្រព្យសកម្ម និងបំណុលដែលជារូបិយប័ណ្ណក្រៅពីដុល្លារអាមេរិកនៅអត្រា ប្តូរប្រាក់នៅចុងឆ្នាំ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល។

(គ) ការបង្ហាញជាប្រាក់រៀល

អនុលោមទៅតាមច្បាប់ស្តីពី គណនេយ្យ និងសវនកម្ម ចុះថ្ងៃទី 11 ខែ មេសា ឆ្នាំ 2016 និង ប្រកាសលេខ 643 MEF PRK ចុះថ្ងៃទី 26 ខែកក្កដា ឆ្នាំ 2007 នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការផ្លាស់ប្តូរ របាយការណ៍ហិរញ្ញវត្ថុពីប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀល គឺត្រូវធ្វើជាចាំបាច់។

ការប្តូរពីប្រាក់ដុល្លារអាមេរិក ទៅប្រាក់រៀល ត្រូវបានបញ្ចូលនៅក្នុង របាយការណ៍ហិរញ្ញវត្ថុគ្រាន់តែ ដើម្បីអនុលោមតាមប្រកាសលេខ ធ7-07-164 ចុះថ្ងៃទី 13 ខែធ្នូ ឆ្នាំ 2007 របស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធទៅនឹងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ហើយរបាយការណ៍នេះត្រូវបានធ្វើឡើងដោយប្រើអត្រាប្តូរប្រាក់ផ្លូវការ ដោយអត្រា 1 ដុល្លារអាមេរិក ស្មើនឹង 4,037 រៀល (2016: 1 ដុល្លារ អាមេរិក ស្មើនឹង 4,037) ដែលបានចេញផ្សាយដោយធនាគារជាតិ នៃកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញជាប្រាក់រៀលមិនត្រូវបានធ្វើ សវនកម្មនោះឡើយ និងមិនត្រូវបកស្រាយថាការបង្ហាញនេះ ជាការប្តូរ ពីប្រាក់ដុល្លារអាមេរិក ទៅប្រាក់រៀលតាមអត្រាប្តូរប្រាក់ខាងលើនេះ ឬ តាមអត្រាប្តូរប្រាក់ណាមួយផ្សេងទៀតឡើយ។

២.៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់នៅក្នុងដៃសមតុល្យ នៅធនាគារជាតិនៃកម្ពុជាដែលមិនមានការកំហិត សមតុល្យនៅ ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានានិងការវិនិយោគរយៈពេលខ្លី ដែលមានកាលវិសាន្តនៅពេលតម្កល់ដំបូងមានរយៈពេល3ខែឬតិចជាង និងដែលធនាគារអាចដកជាសាច់ប្រាក់សម្រាប់គោលបំណងទូទៅនៅ ពេលណាក៏បាន ដោយមិនមានការផ្លាស់ប្តូរតម្លៃធំដុំ។

២.៥ ប្រាក់បញ្ញើតម្កល់តាមច្បាប់

ប្រាក់បញ្ញើតម្កល់តាមច្បាប់ត្រូវបានរក្សាទុកនៅធនាគារជាតិនៃ កម្ពុជា ស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុនៃ ព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុន អប្បបរមា របស់ធនាគារ និងប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវ ដោយធនាគារជាតិនៃកម្ពុជា។ ប្រាក់បញ្ញើតម្កល់តាមច្បាប់ ត្រូវបាន កត់ត្រាតាមតម្លៃដើម។

២.៦ តណាទានផ្តល់ដល់អតិថិជន

តណាទានផ្តល់ដល់អតិថិជនត្រូវបានកត់ត្រានៅក្នុងតារាងតុល្យការ តាមប្រាក់ដើមដកចេញចំនួនទាំងឡាយណាដែលបានលុបចោល និងសំវិធានធនលើតណាទានអាក្រក់ និងជាប់សង្ស័យ។

២.៧ សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ

ធនាគារធ្វើសំវិធានធនសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យដោយផ្អែកលើកម្រិតនៃសំវិធានធនដែលជាតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា ឬធ្វើសំវិធានធនដែលមានហានិភ័យ 100% នៃឥណទានដែលហួសកាលកំណត់សង 83 ថ្ងៃឬលើសពីនេះ។ អ្នកគ្រប់គ្រងជឿជាក់ថាវានឹងអាចឆ្លុះបញ្ចាំងពីសំវិធានធនដែលចាំបាច់ដើម្បីកាត់បន្ថយហានិភ័យដែលទាក់ទងនឹងចរិកលក្ខណៈនៃប្រតិបត្តិការរបស់ធនាគារ។
សមត្ថភាពនៃការទូទាត់សងនេះ ត្រូវបានវាយតម្លៃដោយផ្អែកទៅតាមបទពិសោធន៍នៃការទូទាត់សងពីមុនលក្ខខណ្ឌហិរញ្ញវត្ថុរបស់កូនបំណុលអាជីវកម្ម និងលំហូរសាច់ប្រាក់នាពេលអនាគត លទ្ធភាព និង ការ ស្ម័គ្រចិត្តសងរបស់កូនបំណុល បរិយាកាសហិរញ្ញវត្ថុ និងគុណភាពនៃឯកសារដែលប្រមូលបាន។

បន្ថែមលើគុណភាពនៃព័ត៌មានខាងលើ ចំនួនថ្ងៃហួសកាលកំណត់សងត្រូវបានយកមកគិត។ សំវិធានធនលើឥណទានអាក្រក់និងជាប់សង្ស័យអប្បបរមាត្រូវបានកំណត់ដោយផ្អែកទៅតាមចំណាត់ថ្នាក់ដែលបានកំណត់។ នៅពេលមានព័ត៌មានដែលអាចទុកចិត្តបានថាការបាត់បង់នឹងកើតមានឡើងច្រើនជាងតម្រូវការអប្បបរមានោះសំវិធានធនបន្ថែមនឹងត្រូវបានធ្វើឡើង។ មុនថ្ងៃទី 1 ខែធ្នូ ឆ្នាំ2017 ចំណាត់ថ្នាក់ឥណទាន និងតម្រូវការសំវិធានធនអប្បបរមា៖

ចំណាត់ថ្នាក់	ចំនួនថ្ងៃហួសកាលកំណត់សង	សំវិធានធន
ឥណទានធម្មតា	29**ថ្ងៃ ឬតិចជាង**	1%
ឥណទានឃ្លាំមើល	30 - 89 **ថ្ងៃ**	3%
ឥណទានក្រោមស្តង់ដារ	90 - 179 **ថ្ងៃ**	20%
ឥណទានជាប់សង្ស័យ	180 - 359 **ថ្ងៃ**	50%
ឥណទានចាត់បង់	360**ថ្ងៃ ឬច្រើនជាង**	100%

ក្នុងអំឡុងឆ្នាំនេះធនាគារជាតិនៃកម្ពុជាបានចេញប្រកាសថ្មីលេខ ធ7-017-344 ចុះថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2017 ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិនដែលតម្រូវឱ្យធនាគារ និងស្ថាប័នហិរញ្ញវត្ថុធ្វើសំវិធានធនសម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី និងរយៈពេលវែងដូចខាងក្រោម៖

ចំណាត់ថ្នាក់	ចំនួនថ្ងៃដែលហួស		សំវិធានធន
	កម្ចីរយៈពេលខ្លី	**កម្ចីរយៈពេលវែង**	
	(មួយឆ្នាំ ឬតិចជាង)	**(ច្រើនជាងមួយឆ្នាំ)**	
ឥណទានធម្មតា/ស្តង់ដារ	14 **ថ្ងៃ ឬតិចជាង**	29 **ថ្ងៃ ឬតិចជាង**	1%
ឥណទានឃ្លាំមើល	15 **ថ្ងៃ** - 30 **ថ្ងៃ**	30 **ថ្ងៃ** - 89 **ថ្ងៃ**	3%
ឥណទានក្រោមស្តង់ដារ	31 **ថ្ងៃ** - 60 **ថ្ងៃ**	90 **ថ្ងៃ** - 179 **ថ្ងៃ**	20%
ឥណទានជាប់សង្ស័យ	61 **ថ្ងៃ** - 90 **ថ្ងៃ**	180 **ថ្ងៃ** - 359 **ថ្ងៃ**	50%
ឥណទានចាត់បង់	91 **ថ្ងៃ ឬ ច្រើនជាង**	360 **ថ្ងៃ ឬ ច្រើនជាង**	100%

ការផ្លាស់ប្តូរការចាត់ថ្នាក់និងសំវិធានធនត្រូវបានយកមកអនុវត្តចាប់ពីពេលមានការផ្លាស់ប្តូរ។

ភាពគ្រប់គ្រាន់នៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យត្រូវបានវាយតម្លៃដោយគណៈគ្រប់គ្រងរៀងរាល់ខែ។ លក្ខខណ្ឌទាំងឡាយដែលត្រូវបានពិចារណាក្នុងការវាយតម្លៃទៅលើភាពគ្រប់គ្រាន់នៃ សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យមានដូចជា ទំហំឥណទានបទពិសោធន៍នៃការខាតបង់កន្លងមក លក្ខខណ្ឌសេដ្ឋកិច្ចបច្ចុប្បន្ន និងផលប៉ះពាល់ផ្សេងៗដល់អតិថិជន ស្ថានភាពហិរញ្ញវត្ថុរបស់ អតិថិជន និងស្ថានភាពជាក់ស្តែងនៃឥណទានធៀបនឹងលក្ខខណ្ឌ ដែលបានចែងក្នុងកិច្ចសន្យា។

ការប្រមូលបានមកវិញនូវឥណទាន ដែលបានលុបចោលពីពេលមុន និងការលុបត្រឡប់នូវសំវិធានធនដែលបានកត់ត្រាពីមុន ត្រូវបានទទួលស្គាល់ជាចំណូល ប្រតិបត្តិការផ្សេងៗនៅក្នុងរបាយការណ៍លទ្ធផល។

២.៨ ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាតាមតម្លៃដើម។ ការប៉ាន់ស្មាន ត្រូវបានធ្វើឡើងសម្រាប់គណនីត្រូវទទួលដែលជាប់សង្ស័យ ដោយផ្អែកតាមការត្រួតពិនិត្យចំនួនដែលនៅសល់នាកាលបរិច្ឆេទរាយការណ៍។

២.៩ ទ្រព្យ និងបរិក្ខារ

ផ្នែកនៃទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមតម្លៃដើម ដកវិលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរប្រសិនបើមាន។ នៅពេលដែលធាតុរបស់ទ្រព្យ និងបរិក្ខារ មានអាយុកាលប្រើប្រាស់ខុសៗគ្នា ធាតុទាំងនោះត្រូវបានចាត់ទុកជាផ្នែកផ្សេងគ្នានៃទ្រព្យ និងបរិក្ខារ ។

វិលស់លើទ្រព្យ និងបរិក្ខារ ត្រូវបានបញ្ចូលជាចំណាយក្នុងរបាយការណ៍លទ្ធផលលើមូលដ្ឋានវិលស់ថេរ ផ្អែកលើការប៉ាន់ស្មានអាយុកាលរបស់ទ្រព្យនីមួយៗ តាមអត្រាដូច ខាងក្រោម៖

- ការកែលម្អអគារ 3 – 10 ឆ្នាំ
- គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ 3 – 5 ឆ្នាំ
- គ្រឿងព័ត៌មានវិទ្យាបរិក្ខារ និងកុំព្យូទ័រ 3 – 5 ឆ្នាំ
- បរិក្ខារការិយាល័យ 2 – 3 ឆ្នាំ

ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងបរិក្ខារដែលបានទទួលស្គាល់រួចមក ត្រូវបានរួមបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យនោះ នៅពេលដែលអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតដែលនឹងអាចមានឡើងសម្រាប់ធនាគារ លើសពីស្តង់ដារដើមនៃទ្រព្យសកម្មដែលមានស្រាប់។ រាល់ការចំណាយបន្ទាប់ផ្សេងទៀតត្រូវបានទទួលស្គាល់ជាបន្ទុកចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

ចំណេញឬខាតពីការបោះចោលឬការលក់ចេញនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកំណត់ ដោយភាពខុសគ្នារវាងប្រាក់ចំណូលសុទ្ធពីការលក់ និងតម្លៃយោងនៃទ្រព្យ និងបរិក្ខារនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលនៅថ្ងៃបោះចោល ឬលក់ចេញ។

ទ្រព្យ និងបរិក្ខារ ដែលបានដកវិលស់អស់ហើយ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូត ដល់ថ្ងៃដែលទ្រព្យ និងបរិក្ខារទាំងនោះ ត្រូវបានលក់ ឬលុបចោល ។

២.១០ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីរួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលរាប់បញ្ចូលថ្លៃដើមនៅពេលទិញ ដែលមិនមែនជាផ្នែកភ្ជាប់ប្រតិបត្តិការរបស់កុំព្យូទ័រ ហើយវាត្រូវបានកំណត់តម្លៃដោយយកថ្លៃដើម ដកវិលស់បង្គរ និងឱនភាពនៃតម្លៃប្រសិនបើមាន។

វិលស់ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផល ដោយប្រើវិធីសាស្ត្រវិលស់ថេរក្នុងរយៈពេល 5 ឆ្នាំ។

២.១១ ឱនភាពនៃតម្លៃ

(ក) ទ្រព្យសកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃនាកាលបរិច្ឆេទ រាយការណ៍នីមួយៗដើម្បីកំណត់ថាតើមានភស្តុតាងណាមួយដែលបង្ហាញថាទ្រព្យសកម្មហិរញ្ញវត្ថុទាំងនោះមានឱនភាពនៃតម្លៃ។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ ប្រសិនបើមានហេតុការណ៍មួយឬច្រើន ជះឥទ្ធិពលជាអវិជ្ជមានទៅលើលំហូរសាច់ប្រាក់ដែលប៉ាន់ស្មាននាពេលអនាគតដល់ទ្រព្យសកម្មនោះ។ ករណីនេះមិនត្រូវបានអនុវត្តសម្រាប់តណាទានផ្តល់ដល់អតិថិជននោះទេ ដោយវាត្រូវបានបង្ហាញនៅក្នុងគោលការណ៍គណនេយ្យដោយឡែកនៅក្នុងកំណត់សម្គាល់ 2.7។

រាល់ទ្រព្យសកម្មហិរញ្ញវត្ថុទោលសារវន្ត ត្រូវបានត្រួតពិនិត្យឱនភាពនៃតម្លៃតាមមូលដ្ឋានទោល។ ទ្រព្យសកម្មនៅសល់ ត្រូវបានវាយតម្លៃជារួមក្នុងក្រុមទ្រព្យសកម្មដែលមានហានិភ័យឥណទានស្រដៀងគ្នា។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវដកចេញវិញនៅក្នុងរបាយការណ៍លទ្ធផល ប្រសិនបើការដកចេញ អាចពាក់ព័ន្ធជាមួយនឹងព្រឹត្តិការណ៍ដែលកើតឡើងក្រោយពីការទទួលស្គាល់ការខាតបង់ពីឱនភាព។

(ខ) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្ម មិនមែនហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗដើម្បីកំណត់ថាតើមានសញ្ញាណាមួយដែលបង្ហាញថា ទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ។ ប្រសិនបើមានសញ្ញានោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលបានវិញរបស់ទ្រព្យសកម្ម ត្រូវបានធ្វើឡើង។

តម្លៃដែលអាចទទួលមកវិញបាននៃទ្រព្យសកម្មឬឯកតាបង្កើតសាច់ប្រាក់ គឺមានតម្លៃធំជាង តម្លៃសម្រាប់ប្រើប្រាស់ និងតម្លៃសមស្របដកចំណាយដើម្បីលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់សាច់ប្រាក់រំពឹងថានឹងទទួលបាននាពេលអនាគតត្រូវបានធ្វើអប្បហារទៅតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណនៃតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ។ សម្រាប់គោលបំណងនៃការត្រួតពិនិត្យលើឱនភាពនៃតម្លៃទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចបំផុត ដែលអាចបង្កើតសាច់ប្រាក់ពីការបន្តការប្រើប្រាស់ដោយមិនពឹងផ្អែកខ្លាំងលើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃ (“ឯកតាបង្កើតសាច់ប្រាក់”)។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មមួយ ឬ ឯកតាបង្កើតសាច់ប្រាក់ មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកបានវិញ។ ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល

២.១២ ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានកត់ត្រាតាមតម្លៃដើមនៅពេលដំបូង និងបន្ទាប់មកទៀតត្រូវបានកត់ត្រាទៅតាមប្រាក់ដើមដែលនៅសល់។

២.១៣ សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយមានលទ្ធភាពដែលតម្រូវអោយមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈសារវន្ត សំវិធានធនត្រូវបានកំណត់ដោយអប្បហារលំហូរសាច់ប្រាក់រំពឹងទុកនាពេលអនាគតដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណនៃតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ ។

២.១៤ ការទទួលស្គាល់ប្រាក់ចំណូល

ចំណូលពីការប្រាក់ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានបង្គរ។ ចំពោះឥណទានដែលបានចាត់ថ្នាក់ថា មិនដំណើរការការកត់ត្រាចំណូលពីការប្រាក់ត្រូវបានព្យួរហូតដល់មានសំណងជាសាច់ប្រាក់វិញ។ ការប្រាក់លើឥណទានត្រូវបានគណនា ដោយប្រើវិធីសាស្ត្រថយចុះនៃសមតុល្យប្រាក់ដើមដែលនៅសល់រៀងរាល់ខែ។

កម្រៃលើកិច្ចសន្យាត្រូវបានទទួលស្គាល់ជាចំណូលនៅពេលដែលឥណទានត្រូវបានផ្តល់ឲ្យទៅអតិថិជន។

កម្រៃសេវាកម្ម ត្រូវបានទទួលស្គាល់ នៅពេលដែលសេវាកម្មត្រូវបានបំពេញ។

២.១៥ ចំណាយលើការប្រាក់

ចំណាយលើការប្រាក់ទៅលើប្រាក់បញ្ញើរបស់អតិថិជន ត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរ ។

២.១៦ ភតិសន្យា

ការជួលដែលចំណែកភាគច្រើននៃហានិភ័យ និងផលប្រយោជន៍នៃកម្មសិទ្ធិ ត្រូវបានរក្សាទុកដោយភតិបតីត្រូវបានចាត់ថ្នាក់ជាការជួលតាមកិច្ចសន្យាប្រតិបត្តិការ។ ថ្លៃឈ្នួលដែលបានបង់លើភតិសន្យាប្រតិបត្តិការត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផល ដោយផ្អែកលើមូលដ្ឋានរំលស់ថេរទៅតាមពេលកំណត់នៃការជួល។ កិច្ចសន្យាភតិសន្យាមិនត្រូវបានទទួលស្គាល់ជាបំណុលរហូតដល់ធនាគារមានកាតព្វកិច្ចក្នុងការទូទាត់សង។

២.១៧ ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និង ពន្ធពន្យារ

ពន្ធលើប្រាក់ចំណេញ ឬខាតក្នុងការិយបរិច្ឆេទ រួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ ពន្ធលើប្រាក់ចំណេញត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងទុកថា ត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធក្នុងការិយបរិច្ឆេទ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តមួយផ្នែកធំនាកាលបរិច្ឆេទរាយការណ៍ ជាមួយនឹងនិយ័តភាពណាមួយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

ពន្ធពន្យារ ត្រូវបានកត់ត្រាតាមវិធីសាស្ត្រតារាងតុល្យការទៅលើភាពលំអៀងជាបណ្តោះអាសន្នរវាង តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងប្រើសម្រាប់ការគិតពន្ធ។ ចំនួននៃប្រាក់ពន្ធពន្យារដែលបានកំណត់នោះ គឺផ្អែកលើការរំពឹងទុកថានឹងទទួលបាន ឬការទូទាត់ដែលនឹងកើតឡើងលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល ដោយប្រើអត្រាពន្ធដែលបានកំណត់នៅកាលបរិច្ឆេទរាយការណ៍។

ទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់តែក្នុងករណីអាចនឹងកើតមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតដែលអាចប្រើប្រាស់ដើម្បីកាត់កងជាមួយនឹងភាពខុសគ្នាបណ្តោះអាសន្ន។ ទ្រព្យសកម្មពន្ធពន្យាត្រូវបានពិនិត្យឡើងវិញរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយក្នុងករណីដែលមិនអាចមានអត្ថប្រយោជន៍ពន្ធអាចទទួលបាន។

២.១៨ ការបង្គត់លេខ

តួលេខនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្គត់សម្រាប់ប្រាក់ដុល្លារអាមេរិក និងខ្ទង់ពាន់សម្រាប់ប្រាក់រៀល។

៣ ការប៉ាន់ស្មាន និងការវិនិច្ឆ័យលើគណនេយ្យសំខាន់ៗ

៣.១ ប្រភពសំខាន់ៗនៃការប៉ាន់ស្មានមិនច្បាស់លាស់

ធនាគារធ្វើការប៉ាន់ស្មាន និងសន្មត ដែលប៉ះពាល់លើតួលេខនៃទ្រព្យសកម្មនិងបំណុល។ ការប៉ាន់ស្មាន និងការវិនិច្ឆ័យត្រូវបានវាយតម្លៃជាបន្តបន្ទាប់ដោយផ្អែកទៅលើបទពិសោធន៍នាពេលកន្លងមក និងកត្តាផ្សេងៗ ដូចជាការរំពឹងទុកអំពីហេតុការណ៍នាពេលអនាគត ដែលគេជឿថាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ។

(ក) សំវិធានធនលើឥណទានអាក្រក់ និង ជាប់សង្ស័យ

ធនាគារធ្វើសំវិធានធនសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យដោយផ្អែកលើកម្រិតនៃសំវិធានធនដែលជាតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា ឬសំវិធានធនដែលមានហានិភ័យ 100% នៃឥណទានដែលហួសកាលកំណត់សង 83 ថ្ងៃឬលើសពីនេះ។ អ្នកគ្រប់គ្រងជឿជាក់ថាវា នឹងអាចឆ្លុះបញ្ចាំងពីសំវិធានធនដែលចាំបាច់ដើម្បីកាត់បន្ថយហានិភ័យដែលទាក់ទងនឹងចរិកលក្ខណៈនៃប្រតិបត្តិការរបស់ធនាគារ។

អនុលោមតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា រាល់ឥណទាន ត្រូវបានចាត់ចំណាត់ថ្នាក់ដោយយោងទៅតាមលទ្ធភាពនៃការទូទាត់សងរបស់អ្នកខ្ចីប្រាក់។ លទ្ធភាពនៃការទូទាត់សងនេះ ត្រូវបានវាយតម្លៃដោយផ្អែកទៅតាមបទពិសោធន៍នៃការទូទាត់សងពីមុនលក្ខខណ្ឌហិរញ្ញវត្ថុរបស់កូនបំណុលអាជីវកម្ម និងលំហូរសាច់ប្រាក់នាពេលអនាគតលទ្ធភាព និងការតាំងចិត្តសងរបស់កូនបំណុល ស្ថានភាពហិរញ្ញវត្ថុ និងគុណភាពនៃឯកសារ ដែលប្រមូលបាន។

បន្ថែមលើគុណភាពនៃព័ត៌មានខាងលើ ចំនួនថ្ងៃដែលហួសកាលកំណត់សងក៏ត្រូវបានយកមករាប់បញ្ចូលដែរ។ សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យអប្បបរមា ត្រូវបានកំណត់ដោយផ្អែកទៅតាមចំណាត់ថ្នាក់ដែលបានកំណត់។ នៅពេលមានព័ត៌មានដែលអាចទុកចិត្តបានកំណត់ថា ការបាត់បង់នឹង កើតមានឡើងច្រើនជាងតម្រូវការអប្បបរមា នោះសំវិធានធនបន្ថែមត្រូវបានធ្វើឡើង។

(ខ) ពន្ធលើប្រាក់ចំណេញ

ប្រព័ន្ធពន្ធ ត្រូវបានបែងចែកជាច្រើនប្រភេទ និងមានការផ្លាស់ប្តូរច្បាប់ជារឿយៗដែលមានលក្ខណៈមិនច្បាស់លាស់ផ្ទុយគ្នា និងអាស្រ័យទៅលើការបកស្រាយ។ ជាទូទៅ មានការបកស្រាយខុសៗគ្នាក្នុងចំណោមអាជ្ញាធរពន្ធដារ និងដៃនសម្តកិច្ចផ្សេងៗគ្នា។ ពន្ធត្រូវបានត្រួតពិនិត្យដោយអាជ្ញាធរពន្ធដារជាច្រើនរូប ដែលបានទទួលសិទ្ធិស្របច្បាប់ក្នុងការកំណត់ប្រាក់ពិន័យ និងការប្រាក់លើបំណុលពន្ធ។ កត្តាទាំងនេះអាចធ្វើអោយមានការប៉ះពាល់ដល់ការបង់ពន្ធរបស់សាខាជាសារវន្ត។ គណៈគ្រប់គ្រងជឿជាក់ថាពួកគេបានយល់ដឹងច្បាប់ពន្ធដែលពាក់ព័ន្ធ និងបានធ្វើការគិតបំណុលពន្ធដោយផ្អែកលើការយល់ឃើញរបស់ពួកគេចំពោះច្បាប់ពន្ធបច្ចុប្បន្ន។ ទោះបីជាយ៉ាងណាអាជ្ញាធរដែលពាក់ព័ន្ធប្រហែលជាមានការបកស្រាយផ្សេងៗគ្នាហើយផលប៉ះពាល់អាចមានជាសារវន្ត។

៣.២ ការវិនិច្ឆ័យសំខាន់ៗក្នុងការអនុវត្តគោលនយោបាយគណនេយ្យ

មិនមានការវិនិច្ឆ័យសំខាន់ៗដែលធ្វើឡើងដោយគណៈគ្រប់គ្រងក្នុងដំណើរការអនុវត្តគោលនយោបាយគណនេយ្យដែលមានឥទ្ធិពលជាសារវន្តទៅលើចំនួនទឹកប្រាក់ ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុក្រៅពីការប៉ាន់ស្មាន ដែលបានរៀបរាប់ខាងលើឡើយ។

៤ សាច់ប្រាក់ក្នុងដៃ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ប្រាក់ដុល្លារអាមេរិក	242,884	980,523	185,874	750,373

៥ សមតុល្យនៅធនាគារជាតិនៃកម្ពុជា

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
គណនីចរន្ត	12,384	49,994	22,343	90,199
ប្រាក់តម្កល់ធានាលើដើមទុន*	625,000	2,523,125	500,000	2,018,500
	637,384	**2,573,119**	**522,343**	**2,108,699**

* ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-00-05 ចុះថ្ងៃទី 11 ខែ មករា ឆ្នាំ 2000 ស្តីពីអាជ្ញាប័ណ្ណនៃធនាគារឯកទេស ធនាគារឯកទេសត្រូវរក្សាទុកប្រាក់តម្កល់ធានាលើដើមទុន នៅធនាគារជាតិនៃកម្ពុជា ចំនួន 5% នៃដើមទុនចុះបញ្ជី។ ប្រាក់តម្កល់នេះមិនអាចត្រូវបានប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារបាននោះទេ ហើយនឹងត្រូវបង្វិលឲ្យធនាគារវិញនៅពេលដែលក្រុមហ៊ុន ស្ម័គ្រចិត្ត បញ្ចប់អាជីវកម្មរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រាក់តម្កល់ធានាលើដើមទុន ទទួលបានការប្រាក់តាមអត្រាចន្លោះ ពី 0.32% to 0.36% ក្នុងមួយឆ្នាំ (2016: 0.2% ដល់ 0.22%)។

៦ សមតុល្យនៅធនាគារនានា

ប្រាក់បញ្ញើគឺជាគណនីចរន្ត ដែលដាក់ជាប្រាក់ដុល្លារអាមេរិកនៅធនាគារក្នុងស្រុក និងមិនទទួលបានការប្រាក់ នោះទេ។

៧ តណាទានផ្តល់ដល់អតិថិជន

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
តណាទានឯកត្តជន	37,276,190	150,483,979	34,527,711	139,388,369
	37,276,190	**150,483,979**	**34,527,711**	**139,388,369**
សំវិធានធនសម្រាប់តណាទានអាក្រក់ និង ជាប់សង្ស័យ				
សំវិធានធនជាក់លាក់	(728,384)	(2,940,486)	(402,984)	(1,626,846)
សំវិធានធនទូទៅ	(591,518)	(2,387,958)	(767,501)	(3,098,403)
	(1,319,902)	(5,328,444)	(1,170,485)	(4,725,249)
តណាទានផ្តល់ដល់អតិថិជនសុទ្ធ	**35,956,288**	**145,155,535**	**33,357,226**	**134,663,120**

បម្រែបម្រួលនៃសំវិធានធនសម្រាប់ឥណទានអាក្រក់ និង ជាប់សង្ស័យមានដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
នាថ្ងៃទី 1 ខែ មករា	1,170,485	4,725,249	748,013	3,019,728
សំវិធានធនក្នុងឆ្នាំ	1,406,989	5,680,015	1,271,981	5,134,987
ការលុបចេញ	(1,257,572)	(5,076,820)	(849,509)	(3,429,466)
នាថ្ងៃទី 31 ខែ ធ្នូ	**1,319,902**	**5,328,444**	**1,170,485**	**4,725,249**

ឥណទានដុលត្រូវបានវិភាគមានដូចខាងក្រោម៖

(ក) តាមចំណាត់ថ្នាក់ឥណទាន

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ពុំមានការធានា				
ឥណទានស្តង់ដារ	35,094,851	141,677,913	32,902,287	132,826,533
ឥណទានឃ្លាំមើល	938,170	3,787,392	610,883	2,466,135
ឥណទានក្រោមស្តង់ដារ	374,774	1,512,963	408,709	1,649,958
ឥណទានជាប់សង្ស័យ	462,116	1,865,562	605,832	2,445,743
ឥណទានបាត់បង់	406,279	1,640,149	-	-
	37,276,190	**150,483,979**	**34,527,711**	**139,388,369**

* ឥណទានដែលពុំមានការធានាគឺជាឥណទានដែលពុំមានវត្ថុបញ្ចាំ។

(ខ) តាមកាលកំណត់

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
រយៈពេល 1 ខែ	13,902,335	56,123,726	2,989,486	12,068,555
1 ខែ ទៅ 3 ខែ	705,832	2,849,444	2,601,760	10,503,305
3 ខែ ទៅ 12 ខែ	9,213,837	37,196,260	10,391,076	41,948,774
ពី 1 ឆ្នាំទៅ 5 ឆ្នាំ	13,095,875	52,868,047	18,545,389	74,867,735
លើសពី 5 ឆ្នាំ	358,311	1,446,502	-	-
	37,276,190	**150,483,979**	**34,527,711**	**139,388,369**

(គ) តាមផ្នែកសេដ្ឋកិច្ច

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ការទិញយានយន្តដោយបង់រំលស់	12,243,672	49,427,704	10,980,215	44,327,128
តំណាងប្រើប្រាស់ផ្ទាល់ខ្លួន	9,454,787	38,168,975	8,421,061	33,995,823
ការទិញបង់រំលស់ទូទៅ	7,958,063	32,126,700	7,565,930	30,543,659
កាតឥណទាន	5,517,618	22,274,624	2,940,607	11,871,230
កសិកម្ម	2,102,050	8,485,976	4,619,898	18,650,529
	37,276,190	**150,483,979**	**34,527,711**	**139,388,369**

(ឃ) តាមរូបិយប័ណ្ណ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ប្រាក់ដុល្លារអាមេរិក	**37,276,190**	**150,483,979**	**34,527,711**	**139,388,369**

នៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2016 ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីប្រកាសលេខ ធ7-016-334 ស្តីពីការផ្តល់តំណាងជារូបិយវត្ថុជាតិរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលប្រកាសនេះតម្រូវអោយគ្រប់គ្រឹះស្ថានទាំងអស់ មានតំណាងជារូបិយវត្ថុជាតិ (រៀល) យ៉ាងតិច 10% នៃសំពាធតំណាងសរុប។ ធនាគារ តម្រូវអោយអនុវត្តប្រកាសនេះអោយបានពេញលេញ យ៉ាងយូរត្រឹម ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ។

(ង) តាមនិវាសនដ្ឋាន

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
និវាសនជន	**37,276,190**	**150,483,979**	**34,527,711**	**139,388,369**

(ច) តាមទំនាក់ទំនង

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ពាន់រៀល	ពាន់រៀល
តំណាងផ្តល់ដល់អតិថិជនខាងក្រៅ	37,072,892	149,663,265	34,359,843	138,710,686
តំណាងផ្តល់ដល់បុគ្គលិក	203,298	820,714	167,868	677,683
	37,276,190	**150,483,979**	**34,527,711**	**139,388,369**

(ឆ) តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)

	2017	2016
តំណាងឯកត្តជន	**7.08% - 43.80%**	**7.08% - 43.92%**

៨ ទ្រព្យសកម្មផ្សេងៗ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ការប្រាក់ត្រូវទទួល	868,799	3,507,340	776,350	3,134,125
គណនីត្រូវទទួល	724,153	2,923,406	540,454	2,181,813
ប្រាក់បង់មុន និងប្រាក់តម្កល់	502,458	2,028,423	368,851	1,489,051
ចំណាយបង់មុន	93,660	378,105	51,376	207,405
ផ្សេងៗ	133,163	537,581	41,933	169,284
	2,322,233	**9,374,855**	**1,778,964**	**7,181,678**

៩ ទ្រព្យ និងបរិក្ខារ

	ការកែលម្អអាគារជួល	គ្រឿងសង្ហារឹម និងបរិក្ខារភ្ជាប់	បរិក្ខារការិយាល័យ	កុំព្យូទ័រ និងបរិក្ខារកុំព្យូទ័រ	ទ្រព្យ និងបរិក្ខារកំពុងសាងសង់	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ថ្លៃដើម						
នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2017	1,173,279	186,818	182,449	1,033,594	-	2,576,140
ការទិញបន្ថែម	476,986	30,990	199,319	620,633	366,207	1,694,135
ការលុបចោល	(115,295)	-	(3,998)	-	-	(119,293)
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	**1,534,970**	**217,808**	**377,770**	**1,654,227**	**366,207**	**4,150,982**
ដក៖ រំលស់បង្គរ						
នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2017	(683,503)	(74,331)	(91,371)	(535,808)	-	(1,385,013)
រំលស់ក្នុងឆ្នាំ	(236,594)	(53,580)	(89,074)	(288,838)	-	(668,086)
ការលុបចោល	115,295	-	3,998	-	-	119,293
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	**(804,802)**	**(127,911)**	**(176,447)**	**(824,646)**	**-**	**(1,933,806)**
តម្លៃយោង						
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	730,168	89,897	201,323	829,581	366,207	2,217,176
សមមូលនឹងពាន់រៀល	**2,947,688**	**362,914**	**812,741**	**3,349,018**	**1,478,379**	**8,950,740**

	ការកែលម្អអាគារជួល	គ្រឿងសង្ហារឹម និងបរិក្ខារភ្ជាប់	បរិក្ខារការិយាល័យ	កុំព្យូទ័រ និងបរិក្ខារកុំព្យូទ័រ	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
តម្លៃដើម					
នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2016	934,515	112,476	104,396	921,801	2,073,188
ការទិញបន្ថែម	241,914	74,905	95,555	114,274	526,648
ការលុបចោល	(3,150)	(563)	(17,502)	(2,481)	(23,696)
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	**1,173,279**	**186,818**	**182,449**	**1,033,594**	**2,576,140**
ដក៖ រំលស់បង្គរ					
នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2016	395,696	36,457	63,272	240,303	735,728
រំលស់ក្នុងឆ្នាំ	290,942	38,413	45,272	297,719	672,346
ការលុបចោល	(3,135)	(539)	(17,173)	(2,214)	(23,061)
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	**683,503**	**74,331**	**91,371**	**535,808**	**1,385,013**
តម្លៃយោង					
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	489,776	112,487	91,078	497,786	1,191,127
សមមូលនឹងពាន់រៀល	**1,977,226**	**454,110**	**367,682**	**2,009,562**	**4,808,580**

១០ ទ្រព្យសកម្មអរូបី

	កម្មវិធីកុំព្យូទ័រ	កម្មវិធីកំព្យូទ័រកំពុងតម្លើង	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ថ្លៃដើម			
នាថ្ងៃទី1 ខែ មករា ឆ្នាំ 2017	3,266,213	-	3,266,213
ការទិញបន្ថែម	25,495	524,778	550,273
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	**3,291,708**	**524,778**	**3,816,486**
ដក៖ រំលស់បង្គរ			
នាថ្ងៃទី1 ខែ មករា ឆ្នាំ 2017	(976,619)	-	(976,619)
រំលស់ក្នុងឆ្នាំ	(649,024)	-	(649,024)
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	**(1,625,643)**	**-**	**(1,625,643)**
តម្លៃយោង			
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	1,666,065	524,778	2,190,843
សមមូលនឹងពាន់រៀល	**6,725,904**	**2,118,529**	**8,844,433**

	កម្មវិធីកុំព្យូទ័រ	កម្មវិធីកំព្យូទ័រកំពុងតម្លើង	សរុប
ថ្លៃដើម			
នាថ្ងៃទី1 ខែ មករា ឆ្នាំ 2016	2,983,565	-	2,983,565
ការទិញបន្ថែម	282,648	-	282,648
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	**3,266,213**	**-**	**3,266,213**
ដក៖ រំលស់បង្គរ			
នាថ្ងៃទី1 ខែ មករា ឆ្នាំ 2016	(333,028)	-	(333,028)
រំលស់ក្នុងឆ្នាំ	(643,591)	-	(643,591)
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	**(976,619)**	**-**	**(976,619)**
តម្លៃយោង			
នាថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2016	2,289,594	-	2,289,594
សមមូលនឹងពាន់រៀល	**9,243,091**	**-**	**9,243,091**

១១ បំណុលផ្សេងៗ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
គណនីត្រូវទូទាត់ឲ្យអ្នកចែកចាយ និងអ្នកផ្គត់ផ្គង់	874,826	3,531,673	523,111	2,111,799
ចំណាយបង្គរ	141,556	571,462	178,826	721,921
ប្រាក់បង់មុនពីអតិថិជន	88,511	357,319	96,040	387,713
បំណុលពន្ធផ្សេងៗ	74,587	301,108	71,545	288,827
ការប្រាក់ត្រូវបង់	74,409	300,389	44,867	181,128
ការប្រាក់ព្យួរទុក	32,583	131,538	11,010	44,447
ផ្សេងៗ	232,547	938,791	66,630	268,986
	1,519,019	**6,132,280**	**992,029**	**4,004,821**

១២ ពន្ធលើប្រាក់ចំណេញ

(ក) ពន្ធពន្យារ, សុទ្ធ

ទ្រព្យសកម្ម និងបំណុលពន្ធពន្យារ ត្រូវបានកាត់កងនៅពេលមានការអនុញ្ញាតដោយច្បាប់ និងស្ថិតក្រោមអាជ្ញាធរពន្ធតែមួយ ។ ចំនួនដែលបានកាត់កងរួចហើយមានដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ពន្ធពន្យារជាទ្រព្យសកម្ម	246,414	994,774	200,776	810,533
ពន្ធពន្យារជាបំណុល	(521)	(2,104)	-	-
	245,893	**992,670**	**200,776**	**810,533**

បម្រែបម្រួលទ្រព្យសកម្មពន្ធពន្យារសុទ្ធ មានដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
នាថ្ងៃទី1 ខែ មករា	200,776	810,533	59,253	239,975
ផ្ទេរចូលក្នុងទៅរបាយការណ៍លទ្ធផល	39,933	161,209	141,523	571,328
ការធ្វើវិសោធនកម្មលើពន្ធពីឆ្នាំមុន	5,184	20,928	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	(770)
	245,893	**992,670**	**200,776**	**810,533**

ទ្រព្យសកម្ម/(បំណុល) ពន្ធពន្យារមានដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
រំលស់	71,437	288,391	27,269	110,085
សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ	123,933	500,318	157,165	634,475
ប្រាក់ឧបត្ថម្ភបង្គរ	37,702	152,203	-	-
ប្រាក់ចំណូលមិនទាន់ទទួលស្គាល់	13,342	53,862	15,114	61,015
ខាតពីលំអៀងអត្រាប្តូរប្រាក់	(521)	(2,104)	1,228	4,958
	245,893	**992,670**	**200,776**	**810,533**

(ខ) បំណុលពន្ធលើប្រាក់ចំណេញ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
នាថ្ងៃទី 1 ខែ មករា	139,195	561,930	280,305	1,135,235
ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ	118,390	477,940	219,900	887,736
ឥណទានពន្ធយោងទៅមុខ	-	-	7,449	30,072
ពន្ធដែលបានបង់	(245,288)	(990,228)	(368,459)	(1,487,469)
ការធ្វើវិសោធនកម្មលើពន្ធពីឆ្នាំមុន	5,184	20,929	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	(3,644)
នាថ្ងៃទី 31 ខែ ធ្នូ	**17,481**	**70,571**	**139,195**	**561,930**

អនុលោមទៅតាមច្បាប់ពន្ធនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញ ដោយគណនាតាមអត្រា 20% នៃប្រាក់ចំណេញជាប់ពន្ធ ឬក៏បង់ពន្ធអប្បបរមាដោយគណនាតាមអត្រា 1% នៃប្រាក់ចំណូលសរុប ដោយកំណត់យកចំនួនពន្ធ ត្រូវបង់ណាដែលធំជាង ។

(គ) ចំណាយពន្ធលើប្រាក់ចំណេញ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ	118,390	477,940	219,900	887,736
ចំណាយពន្ធពន្យារ	(39,933)	(161,209)	(141,523)	(571,328)
នាថ្ងៃទី 31 ខែ ធ្នូ	**78,457**	**316,731**	**78,377**	**316,408**

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ប្រាក់ចំណេញមុនដកពន្ធ	154,674	624,418	95,134	384,057
ពន្ធលើប្រាក់ចំណេញគណនាតាមអត្រាពន្ធជាផ្លូវការ	30,935	124,885	19,027	76,812
ចំណាយមិនអាចកាត់កងបាន	41,815	168,807	38,126	153,915
វិសោធនកម្មពន្ធពីការិយបរិច្ឆេទមុន	5,184	20,928		
កង្វះសំវិធានធននៅការិយបរិច្ឆេទមុន	-	-	15,782	63,712
ផលប៉ះពាល់លើសមតុល្យពន្ធពន្យារ	523	2,111	5,442	21,969
ចំណាយពន្ធលើប្រាក់ចំណេញ	**78,457**	**316,731**	**78,377**	**316,408**

ការបង់ពន្ធរបស់ធនាគារត្រូវមានការត្រួតពិនិត្យ និងអនុម័តដោយអាជ្ញាធរពន្ធដារ។ ដោយសារការអនុវត្តច្បាប់ពន្ធនិងបទបញ្ជាផ្សេងៗចំពោះប្រភេទប្រតិបត្តិការផ្សេងៗអាចប្រែប្រួលទៅតាមការបកស្រាយខុសៗគ្នា ចំនួនដែលត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចត្រូវបានផ្លាស់ប្តូរនៅពេលក្រោយ តាមការកំណត់ចុងក្រោយដោយអគ្គនាយកដ្ឋានពន្ធដារ។

១៣ ប្រាក់កម្ចី

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
នាថ្ងៃទី 1 ខែ មករា	28,690,000	115,821,530	21,890,000	88,654,500
កម្ចីក្នុងឆ្នាំ	22,700,000	91,639,900	13,000,000	52,481,000
ការទូទាត់សងក្នុងឆ្នាំ	(20,690,000)	(83,525,530)	(6,200,000)	(25,029,400)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	(284,570)
នាថ្ងៃទី 31 ខែ ធ្នូ	**30,700,000**	**123,935,900**	**28,690,000**	**115,821,530**

ប្រាក់កម្ចីទាំងនេះ ជាប្រាក់កម្ចីពីធនាគារនៅបរទេស ដែលមានអត្រាការប្រាក់ពី 2.14% to 3.30% ក្នុងមួយឆ្នាំ (ឆ្នាំ2016គឺ ពី0.72% ទៅ 2.20%)។

ចំណាយការប្រាក់ក្នុងឆ្នាំមានចំនួន 686,891 ដុល្លារអាមេរិក (ឆ្នាំ2016គឺ 455,710 ដុល្លារអាមេរិក)។

ប្រាក់កម្ចី ត្រូវបានវិភាគបន្ថែមដូចខាងក្រោម៖

(ក) តាមរូបិយប័ណ្ណ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ប្រាក់ដុល្លារអាមេរិក	**30,700,000**	**123,935,900**	**28,690,000**	**115,821,530**

(ខ) តាមកាលកំណត់

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
1 ទៅ 3ខែ	10,000,000	40,370,000	4,300,000	17,359,100
4 ទៅ 12ខែ	6,700,000	27,047,900	21,390,000	86,351,430
លើសមួយឆ្នាំ	14,000,000	56,518,000	3,000,000	12,111,000
	30,700,000	**123,935,900**	**28,690,000**	**115,821,530**

១៤ ដើមទុន

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ភាគហ៊ុនដែលបានចុះបញ្ជី និងបានបង់ 1 ដុល្លារអាមេរិកក្នុងមួយហ៊ុន	**12,500,000**	**50,462,500**	**10,000,000**	**40,370,000**

ព័ត៌មានលម្អិតអំពីដើមទុនមានដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	% នៃភាពជាម្ចាស់កម្មសិទ្ធិ	ចំនួនភាគហ៊ុន1 ដុល្លារអាមេរិក ក្នុងមួយហ៊ុន	% នៃភាពជាម្ចាស់កម្មសិទ្ធិ	ចំនួនភាគហ៊ុន1 ដុល្លារអាមេរិក ក្នុងមួយហ៊ុន
AEON Thana Sinsap (Thailand) Public Company Limited	80%	10,000,000	80%	8,000,000
AEON Financial Service Co., Ltd.	20%	2,500,000	20%	2,000,000
	100%	**12,500,000**	**100%**	**10,000,000**

យោងតាមប្រកាស ធ7-016-117 ចុះថ្ងៃទី 22 ខែ មីនា ឆ្នាំ 2016 លើ "ដើមទុនអប្បបរមាចុះបញ្ជី របស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ" ធនាគារឯកទេសបង្កើតក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុក ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង60ប៊ីលានរៀល(សមមូលនឹង15លានដុល្លារអាមេរិក) ។ ធនាគារត្រូវអោយបំពេញតាមការតម្រូវនេះយ៉ាងយូរ 2 ឆ្នាំគិតពីកាលបរិច្ឆេទនៃប្រកាសនេះ។ នៅថ្ងៃទី16ខែមិថុនា ឆ្នាំ2016 ធនាគារជាតិបានចេញសារាចរណែនាំលេខ ធ7-016-003 ស្តីពីការអនុវត្តប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុតម្រូវអោយ ធនាគារត្រូវបង្កើនដើមទុនចុះបញ្ជីអប្បបរមា ឱ្យបានយ៉ាងតិចពាក់កណ្តាលនៃដើមទុនដែលត្រូវបំពេញ បន្ថែមយ៉ាងយូរត្រឹមដំណាច់ខែ មីនា ឆ្នាំ2017 និងបង្ក្រប់ដើមទុនឱ្យបានគ្រប់ចំនួនយ៉ាងយូរបំផុតត្រឹម ថ្ងៃទី 22 ខែ មីនា ឆ្នាំ2018 ។

នាថ្ងៃទី 16 ខែ មីនា ឆ្នាំ 2017 ធនាគារបានទទួលការអនុម័តពីធនាគារជាតិនៃកម្ពុជា ដើម្បីតំឡើងដើមទុនពីចំនួន 10 លានដុល្លារ ទៅដល់ 12.5 លានដុល្លារ។ នាថ្ងៃចេញរបាយការណ៍នេះ ធនាគារបាននិងកំពុងធ្វើការកែប្រែ លក្ខន្តិក:របស់ធនាគារ ដើម្បីទទួលបានការអនុម័តពីក្រសួងពាណិជ្ជកម្ម ។

១៥ ចំណូលពីការប្រាក់

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
តំណាងផ្តល់ដល់អតិថិជន	9,480,127	38,271,273	8,458,635	34,147,509
សមតុល្យនៅធនាគារជាតិនៃកម្ពុជា និងធនាគារផ្សេងៗ	35,315	142,567	31,248	126,148
ប្រាក់តម្កល់ធានាលើដើមទុន	2,268	9,155	1,059	4,276
	9,517,710	**38,422,995**	**8,490,942**	**34,277,933**

១៦ ចំណូលកម្រៃជើងសារ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
កម្រៃលើចំណាយទូទាត់សង	270,444	1,091,782	87,586	353,585
កម្រៃពីការធានាកាតព្វកិច្ច	204,449	825,361	154,212	622,554
កម្រៃសេវាតំណាង	160,655	648,564	166,442	671,926
ការប្រមូលបានវិញនូវតំណាងដែលបានលុបចោលពីមុន	12,827	51,782	2,768	11,174
កម្រៃផ្សេងៗ	195,267	788,293	122,964	496,406
ខាតពីការប្តូរប្រាក់	(3,527)	(14,238)	(6,135)	(24,767)
	840,115	**3,391,544**	**527,837**	**2,130,878**

១៧ ចំណាយលើបុគ្គលិក

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ប្រាក់ខែ និងប្រាក់ឈ្នួល	3,175,355	12,818,908	2,646,396	10,683,501
ចំណាយលើការបណ្តុះបណ្តាល	106,462	429,787	66,184	267,185
ចំណាយលើការជួលផ្ទះសម្រាប់ បុគ្គលិក	79,177	319,638	75,691	305,565
ចំណាយថ្នាំពេទ្យ	10,544	42,566	11,882	47,968
ផ្សេងៗ	60,786	245,393	57,689	232,889
	3,432,324	**13,856,292**	**2,857,842**	**11,537,108**

១៨ រំលស់

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
រំលស់ទ្រព្យ និងបរិក្ខារ	668,085	2,697,058	672,346	2,714,261
រំលស់ទ្រព្យសកម្មអរូបី	649,025	2,620,115	643,591	2,598,177
	1,317,110	**5,317,173**	**1,315,937**	**5,312,438**

១៩ ចំណាយប្រតិបត្តិការផ្សេងៗ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណាយលើការជួសជុល និងថែទាំ	565,093	2,281,280	419,186	1,692,254
ចំណាយលើការជួលការិយាល័យ	455,658	1,839,491	385,506	1,556,288
ចំណាយលើផ្នែកទីផ្សារ និងការផ្សាយពាណិជ្ជកម្ម	422,044	1,703,794	545,448	2,201,974
ចំណាយលើផ្នែកទំនាក់ទំនង	271,410	1,095,682	236,266	953,806
ចំណាយលើការធ្វើដំណើរ	270,345	1,091,383	233,488	942,591
ចំណាយលើសម្ភារៈការិយាល័យ	240,848	972,303	184,962	746,692
ចំណាយលើការជួលយានយន្ត	213,408	861,528	206,728	834,561
ចំណាយលើសេវាវិជ្ជាជីវៈ	202,811	818,748	141,097	569,609
ចំណាយពន្ធ និងអាជ្ញាប័ណ្ណ	161,452	651,782	211,288	852,970
ចំណាយលើកាតឥណទាន និង ប្រតិបត្តិការទូ ATM	148,524	599,591	53,704	216,803
ចំណាយលើថ្លៃទឹកភ្លើង	101,979	411,689	111,371	449,605
ចំណាយលើធានារ៉ាប់រង	75,334	304,123	82,698	333,852
ការខាតលើការលុបចោលទ្រព្យ និងបរិក្ខារ	-	-	635	2,563
ចំណាយផ្សេងៗ	230,931	932,268	209,798	846,952
	3,359,837	**13,563,662**	**3,022,175**	**12,200,520**

២០ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សម្រាប់ការបង្ហាញក្នុងរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូល មានដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
សាច់ប្រាក់ក្នុងដៃ	242,884	980,523	185,874	750,373
គណនីចរន្តនៅធនាគារជាតិនៃកម្ពុជា	12,384	49,994	22,343	90,199
សមតុល្យនៅធនាគារនានា	2,116,532	8,544,441	1,484,889	5,994,497
	2,371,800	**9,574,958**	**1,693,106**	**6,835,069**

២១ ភតិសន្យា និងយថាភាព

(ក) កិច្ចសន្យាភតិសន្យាប្រតិបត្តិការ

ធនាគារជួលអគារការិយាល័យ ក្រោមភតិសន្យាប្រតិបត្តិការដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
មិនលើសពី 1ឆ្នាំ	387,580	1,564,660	387,904	1,565,968
លើសពី 1ឆ្នាំ តែមិនលើសពី5ឆ្នាំ	225,490	910,303	479,776	1,936,856
	613,070	**2,474,963**	**867,680**	**3,502,824**

(ខ) កិច្ចសន្យាឥណទាន

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
កម្រិតឥណទានដែលមិនទាន់បាន ប្រើប្រាស់	**6,978,595**	**28,172,588**	**7,252,815**	**29,279,614**

(គ) កិច្ចសន្យាចំណាយមូលធន

ការចំណាយមូលធនដែលបានចុះកិច្ចសន្យានៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ប៉ុន្តែមិនទាន់បានកើតឡើងមានដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
មិនលើសពី 1 ឆ្នាំ	**787,470**	**3,179,016**	**-**	**-**

២២ សមតុល្យ និងប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

សមតុល្យ និងប្រតិបត្តិការជាមួយសម្ព័ន្ធញាតិមានដូចខាងក្រោម៖

ទំនាក់ទំនង	ភាគីពាក់ព័ន្ធ
ក្រុមហ៊ុនមេ	ក្រុមហ៊ុនដែលមានកម្មសិទ្ធិ និងការគ្រប់គ្រងភាគច្រើនលើធនាគារ
ក្រុមហ៊ុនសម្ព័ន្ធញាតិ	ក្រុមហ៊ុនដែលនៅក្នុងក្រុមហ៊ុនមេតែមួយរបស់ធនាគារ
គណៈគ្រប់គ្រងសំខាន់ៗ	អ្នកដែលមានអំណាច និងការទទួលខុសត្រូវសម្រាប់ការរៀបចំផែនការ ដឹកនាំ និងត្រួតពិនិត្យសកម្មភាពរបស់ធនាគារផ្ទាល់ ឬមិនផ្ទាល់ រួមទាំងនាយក (មិនថានាយកប្រតិបត្តិឬក៏នាយ័កមិនប្រតិបត្តិ) របស់ធនាគារ។

(ក) សមតុល្យជាមួយនឹងសម្ព័ន្ធញាតិ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំនួនត្រូវទទួល				
ក្រុមហ៊ុនមេ	890	3,593	-	-
ក្រុមហ៊ុនសម្ព័ន្ធញាតិ	13,117	52,953	9,796	39,546
ចំនួនដែលត្រូវបង់				
ក្រុមហ៊ុនមេ	-	-	2,567	10,363
ក្រុមហ៊ុនសម្ព័ន្ធញាតិ	66,573	268,755	115,836	467,630

គណនីត្រូវបង់ទៅសម្ព័ន្ធញាតិ គឺពុំមានការធានា និងគ្មានការប្រាក់ ហើយគ្មានកាលកំណត់ជាក់លាក់ក្នុងការទូទាត់សងឡើយ។

(ខ) ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ

	ដំណាច់ឆ្នាំ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ដំណាច់ឆ្នាំ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ក្រុមហ៊ុនមេ				
ចំណាយទូទាត់សង	1,142	4,610	26,404	106,593
កម្រៃលើថ្នាក់គ្រប់គ្រង	214,272	865,016	-	-
ទំនិញ និងសេវាកម្មដែលទទួលបាន	19	77	106,674	430,643
ក្រុមហ៊ុនសម្ព័ន្ធញាតិ				
ការផ្តល់សេវា	30,572	123,419	64,414	260,039
ចំណាយទូទាត់សង	-	-	13,860	55,953
ទំនិញ និងសេវាកម្មដែលទទួលបាន	1,074,825	4,339,069	788,854	3,184,604
ប្រាក់កម្រៃរបស់គណៈគ្រប់គ្រង	940,085	3,795,123	816,787	3,297,369
ការទូទាត់បំណុលរបស់អតិថិជន	582,890	2,353,127	657,817	2,655,607
ចំណាយការជួល	65,292	263,584	33,792	136,418

(គ) **សំណងនិងអត្ថប្រយោជន៍របស់គណៈគ្រប់គ្រងសំខាន់ៗ**

ចំណាយ រួមបញ្ចូលទាំង អត្ថប្រយោជន៍របស់អភិបាល និងអ្នកគ្រប់គ្រងសំខាន់ៗក្នុងការិយបរិច្ឆេទ មានចំនួន477,920 ដុល្លារអាមេរិក (ឆ្នាំ2016គឺ 554,536 ដុល្លារអាមេរិក) ។

២៣ ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

សកម្មភាពរបស់ធនាគារ ប្រឈមនឹងហានិភ័យហិរញ្ញវត្ថុជាច្រើនដូចជា ហានិភ័យឥណទាន ហានិភ័យ ទីផ្សារ (រួមទាំងហានិភ័យរូបិយប័ណ្ណ ហានិភ័យអត្រាការប្រាក់ និងហានិភ័យតម្លៃ) និងហានិភ័យសាច់ ប្រាក់ងាយស្រួល។ អាជីវកម្មតែងតែប្រឈមមុខនឹងហានិភ័យ ហើយហានិភ័យប្រតិបត្តិការគឺជា ហានិភ័យដែលមិនអាចជៀសបានក្នុងអាជីវកម្ម ។

ធនាគារមិនបានប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ ដូចជាកិច្ចសន្យាប្តូររូបិយប័ណ្ណ និងការប្តូរអត្រាការប្រាក់ដើម្បី គ្រប់គ្រងហានិភ័យទាំងនោះទេ ដោយសារព្រះរាជាណាចក្រកម្ពុជា មិនមានទីផ្សារនិស្សន្ទនៅឡើយ ។

ធនាគារ មានគោលដៅអនុលោមតាមបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ។ ប៉ុន្តែធនាគារទទួលស្គាល់ថា មិនទាន់បានអនុវត្តយ៉ាងពេញលេញនូវការគ្រប់គ្រងហានិភ័យតាមស្តង់ដារអន្តរជាតិនៅឡើយទេ។ ក្រុមប្រឹក្សាភិបាល បានបង្កើតផ្នែកគ្រប់គ្រងហានិភ័យ ដើម្បីបង្កើតប៉ារ៉ាម៉ែត្រដែលអាចឲ្យធនាគារទទួលយកហានិភ័យបាន និងតាមដានសកម្មភាពប៉ារ៉ាម៉ែត្រទាំងនោះ ។

ធនាគារកាន់កាប់ទ្រព្យសកម្ម និងបំណុលដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្មហិរញ្ញវត្ថុ				
សាច់ប្រាក់ក្នុងដៃ	242,884	980,523	185,874	750,373
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	637,384	2,573,119	522,343	2,108,699
សមតុល្យនៅធនាគារនានា	2,116,532	8,544,440	1,484,889	5,994,497
ឥណទានផ្តល់ដល់អតិថិជន	35,956,288	145,155,535	33,357,226	134,663,120

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
ទ្រព្យសកម្មផ្សេងៗ	1,752,582	7,075,174	1,316,804	5,315,938
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប	**40,705,670**	**164,328,791**	**36,867,136**	**148,832,627**
បំណុលហិរញ្ញវត្ថុ				
បំណុលផ្សេងៗ	1,048,822	3,283,833	813,434	3,283,833
គណនីត្រូវទូទាត់សងសម្ព័ន្ធញាតិ	42,783	172,715	115,836	467,630
ប្រាក់កម្ចី	30,700,000	123,935,900	28,690,000	115,821,530
បំណុលហិរញ្ញវត្ថុសរុប	**31,791,605**	**127,392,448**	**29,619,270**	**119,572,993**

(ក) ហានិភ័យប្រតិបត្តិការ

ការខាតបង់ពីហានិភ័យប្រតិបត្តិការ ដែលអាចកើតមានឡើងដោយសារតែកង្វះខាត ឬបរាជ័យនៃដំណើរការផ្ទៃក្នុង ធនធានមនុស្ស និងប្រព័ន្ធ ឬបណ្តាលមកពីកត្តាខាងក្រៅ ត្រូវបានគ្រប់គ្រងតាមរយៈដំណើរការ គ្រប់គ្រងហានិភ័យប្រតិបត្តិការដែលបានបង្កើតរួចហើយ ការត្រួតពិនិត្យ និងការរាយការណ៍ឲ្យបាន ត្រឹមត្រូវពីសកម្មភាពអាជីវកម្ម ធ្វើឡើងដោយផ្នែកត្រួតពិនិត្យ និងគាំទ្រដោយឯករាជ្យពីផ្នែកអាជីវកម្ម និង ការត្រួតពិនិត្យដែលផ្តល់ដោយអ្នកគ្រប់គ្រង ។

ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ រួមមានការបង្កើតរចនាសម្ព័ន្ធអង្គភាព តួនាទី និងទំនួលខុសត្រូវច្បាស់លាស់។ ការត្រួតពិនិត្យផ្ទៃក្នុង និងវិធានការផ្សេងៗត្រូវបានបង្កើតឡើង រួមមានការបង្កើតអ្នកដែលមានអំណាចចុះហត្ថលេខា បង្កើតការត្រួតពិនិត្យលើប្រព័ន្ធប៉ារ៉ាម៉ែត្រ និងការបង្កើតឲ្យមាននីតិវិធី និងការរក្សាទុកឯកសារ។ ទាំងអស់នេះត្រូវបានពិនិត្យឡើងវិញជាបន្តបន្ទាប់ដើម្បីឆ្លើយតបទៅនឹងហានិភ័យប្រតិបត្តិការនៃសកម្មភាពអាជីវកម្មរបស់ខ្លួន។

(ខ) ហានិភ័យឥណទាន

ធនាគារប្រឈមទៅនឹងហានិភ័យឥណទានដែលជាហានិភ័យដែលភាគីជាដៃគូនឹងធ្វើឲ្យមានការខាតបង់ហិរញ្ញវត្ថុរបស់ធនាគារដោយសារតែមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន។ ហានិភ័យឥណទានគឺជាហានិភ័យដ៏សំខាន់បំផុតសម្រាប់អាជីវកម្មរបស់ធនាគារ។ ការប្រឈមនឹងហានិភ័យកើតឡើងដោយសារតែការផ្តល់ឥណទានទៅឲ្យអតិថិជន។ ផ្នែកគ្រប់គ្រងហានិភ័យរបស់ធនាគារគឺជាអ្នកតាមដាននូវហានិភ័យឥណទាន ។

(i) ការវាស់វែងហានិភ័យឥណទាន

ធនាគារ ប៉ាន់ប្រមាណនូវកម្រិតប្រហែលនៃការខកខានមិនទូទាត់សងបំណុលរបស់អ្នកខ្ចីម្នាក់ៗ ដោយអនុលោមតាមគោលនយោបាយ នីតិវិធី និងបទពិសោធន៍ឥណទាន។ ផ្នែកគ្រប់គ្រងហានិភ័យទទួល ខុសត្រូវក្នុងការកំណត់គោលនយោបាយចំណាត់ថ្នាក់ហានិភ័យ។

(ii) ការគ្រប់គ្រងកម្រិតហានិភ័យ និងគោលការណ៍បញ្ជៀសហានិភ័យ

ធនាគារធ្វើប្រតិបត្តិការ និងផ្តល់ឥណទានឲ្យឯកកត្តជនដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារ គ្រប់គ្រងកម្រិត និងពិនិត្យការផ្តោតលើហានិភ័យឥណទាន នៅពេលដែលបានកំណត់រកឃើញ។ ហានិភ័យធំៗ ត្រូវបានកំណត់ដោយធនាគារជាតិនៃកម្ពុជា ដោយមិនឲ្យលើសពី 10% មូលនៃនិធិធនាគារផ្ទាល់សុទ្ធ។

ក្រោមប្រកាសលេខ ធ7-06-226 ធនាគារត្រូវបានតម្រូវ អោយរក្សាអនុបាតយ៉ាងច្រើន 20% ចន្លោះពីហានិភ័យឥណទានរបស់ធនាគារ ទៅនិងមូលនិធិធនាគារផ្ទាល់សុទ្ធ និង អត្ថប្រយោជន៍បុគ្គល។ បរិមាណសរុបនៃហានិភ័យឥណទាន មិនអាចលើស 300% នៃ មូលនិធិធនាគារផ្ទាល់ឡើយ។

(iii) គោលនយោបាយក្នុងការកំណត់ឱនភាពនៃតម្លៃ និងការធ្វើសំវិធានធន

ធនាគារត្រូវបានតម្រូវឱ្យអនុវត្តតាមចំណាត់ក្រុមឥណទាន និងសំវិធានធនអនុលោមទៅតាមប្រកាសថ្មីលេខ ធ7-017-344 ចុះថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2017 ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាននិងអ៊ីមែរមិន។ សូមមើលកំណត់សម្គាល់ 2.7 សម្រាប់ព័ត៌មានលំអិត។

(iv) **ការប្រឈមនឹងហានិភ័យឥណទាន**

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្មក្នុងតារាងតុល្យការ				
សមតុល្យនៅធនាគារនានា	2,116,532	8,544,440	1,484,889	5,994,497
ឥណទានផ្តល់ដល់អតិថិជន	35,956,288	145,155,535	33,357,226	134,663,120
ទ្រព្យសកម្មផ្សេងៗ *	1,752,582	7,075,174	1,316,804	5,315,938
ខ្ទង់ក្រៅតារាងតុល្យការ				
កម្រិតឥណទានមិនទាន់បានប្រើប្រាស់	6,978,595	28,172,588	7,252,815	29,279,614
	46,803,997	**188,947,737**	**43,411,734**	**175,253,169**

តារាងខាងបង្ហាញពីសេណារីយ៉ូករណីអាក្រក់បំផុតនៃហានិភ័យឥណទានសម្រាប់ធនាគារនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017 ដោយមិនរាប់បញ្ចូលឥណទានដទៃ។ សម្រាប់ទ្រព្យសកម្មក្នុងតារាងតុល្យការ ការប្រឈមនឹងហានិភ័យខាងលើគឺផ្អែកលើតម្លៃពិតគណនេយ្យ។

ដូចបានបង្ហាញខាងលើ 76.82% (ឆ្នាំ2016គឺ 76.84%) នៃការប្រឈមសរុបគឺកើតឡើងពីឥណទានផ្តល់ឲ្យអតិថិជន។

គណៈគ្រប់គ្រងជឿជាក់លើសមត្ថភាពរបស់ខ្លួនក្នុងការបន្តត្រួតពិនិត្យ និងរក្សាឲ្យនៅទាបបំផុតនូវការប្រឈមនៃហានិភ័យឥណទានរបស់ធនាគារដែលបណ្តាលមកពីឥណទាន ដោយសារតែធនាគារបានរក្សានីតិវិធីវាយតម្លៃឥណទានមុននឹងសម្រេចផ្តល់ឥណទានទៅឲ្យអតិថិជន។

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
បំណុលពីអតិថិជន				
មិនហួសកាលកំណត់និងមិនទាន់ខាតបង់	35,104,537	141,717,016	32,323,344	130,489,340
ហួសកាលកំណត់និងមិនទាន់ខាតបង់	928,484	3,748,290	578,943	2,337,193
ខាតបង់ជាឯកត្តបុគ្គល	1,243,169	5,018,673	1,625,424	6,561,836
	37,276,190	**150,483,979**	**34,527,711**	**139,388,369**

ឥណទានមិនទាន់ហួសកាលកំណត់ និងមិនទាន់ខាតបង់

ឥណទានផ្តល់ជូនអតិថិជនដែលមិនទាន់ហួសកាលកំណត់ និងមិនទាន់ខាតបង់ មិនត្រូវបានធ្វើសំវិធានធន លុះត្រាតែមានព័ត៌មានផ្សេងៗដែលបង្ហាញផ្ទុយពីនេះ។

ឥណទានហួសកាលកំណត់ និងមិនទាន់ខាតបង់

ឥណទានហួសកាលកំណត់ និងមិនទាន់ខាតបង់ គឺជាឥណទានដែលការទូទាត់សងការប្រាក់ និងប្រាក់ ដើមមានការយឺតយ៉ាវតិចជាង 31 ថ្ងៃ សម្រាប់ឥណទានរយៈពែលខ្លី និងតិចជាង 90 ថ្ងៃសម្រាប់ឥណទានរយៈពេលវែង លុះត្រាតែមានព័ត៌មានផ្សេងៗដែលបង្ហាញផ្ទុយពីនេះ ។

ឥណទានខាតបង់ផ្តល់ដល់អតិថិជន

អនុលោមតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា សំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ ត្រូវបានធ្វើឡើងសម្រាប់ឥណទានហួសកាលកំណត់លើសពី31ថ្ងៃសម្រាប់ឥណទានរយៈពែលខ្លី និងលើសពី90ថ្ងៃសម្រាប់ឥណទានរយៈពេលវែង។ សំវិធានធនអប្បបរមាត្រូវបានធ្វើឡើងទៅតាមការចំណាត់ថ្នាក់របស់ឥណទាននីមួយៗ លើកលែងតែមានព័ត៌មានផ្សេងទៀតអាចបញ្ជាក់ ពីលទ្ធភាពនៃការទូទាត់សងរបស់អ្នកខ្ចី។ គោលនយោបាយគណនេយ្យត្រូវបានបង្ហាញនៅកំណត់ សម្គាល់ 2.7 ។

(គ) ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ គឺជាហានិភ័យនៃការខាតបង់កើតពីការប្រែប្រួលមិនអំណោយផលនៅក្នុងកម្រិតតម្លៃ ឬអត្រាទីផ្សារដែលមានសមាសធាតុសំខាន់ពីរគឺ ហានិភ័យរូបិយប័ណ្ណបរទេស និងហានិភ័យអត្រាការប្រាក់ ។

ធនាគារមិនបានប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ ដូចជាកិច្ចសន្យាប្តូររូបិយប័ណ្ណ និងការប្តូរអត្រាការប្រាក់ ដើម្បីគ្រប់គ្រងហានិភ័យទាំងនោះទេ។

ធនាគារ បានរក្សានូវអនុបាតហានិភ័យរូបិយប័ណ្ណបរទេសជាអប្បបរមា ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

(i) ហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេស

ប្រតិបត្តិការរបស់ធនាគារធ្វើឡើងក្នុងរូបភាពរូបិយប័ណ្ណជាច្រើនប្រភេទ ហើយធនាគារបានប្រឈមមុខនឹងហានិភ័យរូបិយប័ណ្ណផ្សេងៗគ្នា ជាពិសេស គឺប្រាក់រៀល។ ហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេសកើតឡើងពីប្រតិបត្តិការពាណិជ្ជកម្មនាពេលអនាគត និងត្រូវទទួលស្គាល់ជាទ្រព្យសកម្ម និងបំណុលជារូបិយប័ណ្ណដែលមិនមែនជារូបិយប័ណ្ណមុខងាររបស់ធនាគារ ។

សមតុល្យទ្រព្យសកម្ម និងបំណុល ដែលជារូបិយប័ណ្ណផ្សេងទៀត ក្រៅពីដុល្លារអាមេរិក មិនមាន ចំនួនច្រើននោះទេ។ ដូចនេះ ការវិភាគរូបិយប័ណ្ណបរទេសមិនត្រូវបានបង្ហាញឡើយ។

(ii) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺសំដៅលើអស្ថេរភាពនៃចំណូលការប្រាក់សុទ្ធ ដោយសារការប្រែប្រួល នូវកម្រិត អត្រាការប្រាក់ និងការផ្លាស់ប្តូរនៅក្នុងសមាសភាពនៃទ្រព្យសកម្ម និងបំណុល។ ការកើតឡើង នូវហានិភ័យអត្រាការប្រាក់ គឺមានទំនាក់ទំនងជាចម្បងលើឥណទាន បញ្ញើនៅធនាគារ និងប្រាក់កម្ចី។

តារាងខាងក្រោមនេះបង្ហាញនូវអត្រាការប្រាក់ប្រសិទ្ធិភាពនាថ្ងៃតារាងតុល្យការ និងអំឡុងពេលដែល ឧបករណ៍ហិរញ្ញវត្ថុត្រូវបានកំណត់តម្លៃឡើងវិញ ឬដល់កាលកំណត់ណាមួយដែលកើតមុនគេ។

	រហូតដល់ 1 ខែ	>1 - 3 ខែ	>3 - 12 ខែ	>1 - 5 ឆ្នាំ	5 ឆ្នាំ	ពុំមានការប្រាក់	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017							
ទ្រព្យសកម្ម							
សាច់ប្រាក់ក្នុងដៃ	-	-	-	-	-	242,884	242,884
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	-	-	-	-	625,000	12,384	637,384
សមតុល្យនៅធនាគារនានា	-	-	-	-	-	2,116,532	2,116,532
ឥណទាន ផ្តល់ដល់អតិថិជន	13,902,335	705,832	9,213,837	13,095,875	358,311	-	37,276,190
ទ្រព្យសកម្មផ្សេងៗ	-	-	-	-	-	1,752,582	1,752,582
	13,902,335	**705,832**	**9,213,837**	**13,095,875**	**983,311**	**4,124,382**	**42,025,572**
បំណុល							
បំណុលផ្សេងៗ	-	-	-	-	-	1,047,102	1,047,102
គណនីត្រូវទូទាត់សងសម្ព័ន្ធញាតិ	-	-	-	-	-	42,783	42,783
ប្រាក់កម្ចី	10,000,000	1,700,000	-	19,000,000	-	-	30,700,000
	10,000,000	**1,700,000**	**-**	**19,000,000**	**-**	**1,089,885**	**31,789,885**
គំលាតនៃអត្រាការប្រាក់	3,902,335	(994,168)	9,213,837	(5,904,125)	983,311	3,034,497	10,235,687
សមមូលនឹងពាន់រៀល	**15,753,726**	**(4,013,456)**	**37,196,260**	**(23,834,953)**	**3,969,627**	**12,250,264**	**41,321,468**

	រហូតដល់ 1 ខែ	>1 - 3 ខែ	>3 - 12 ខែ	>1 - 5 ឆ្នាំ	5 ឆ្នាំ	ពុំមានការប្រាក់	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016							
ទ្រព្យសកម្ម							
សាច់ប្រាក់ក្នុងដៃ	-	-	-	-	-	185,874	185,874
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	-	-	-	-	500,000	22,343	522,343
សមតុល្យនៅធនាគារនានា	-	-	-	-	-	1,484,889	1,484,889
ឥណទានផ្តល់ដល់អតិថិជន	2,989,486	2,601,760	10,391,076	17,530,848	-	1,014,541	34,527,711
ទ្រព្យសកម្មផ្សេងៗ	-	-	-	-	-	1,314,488	1,314,488
	2,989,486	**2,601,760**	**10,391,076**	**17,530,848**	**500,000**	**4,022,135**	**38,035,305**
បំណុល							
បំណុលផ្សេងៗ	-	-	-	-	-	813,434	813,434
គណនីត្រូវទូទាត់សងសម្ព័ន្ធញាតិ	-	-	-	-	-	115,836	115,836
ប្រាក់កម្ចី	-	4,300,000	21,390,000	3,000,000	-	-	28,690,000
	-	**4,300,000**	**21,390,000**	**3,000,000**	**-**	**929,270**	**29,619,270**
គំលាតនៃអត្រាការប្រាក់	2,989,486	(1,698,240)	(10,998,924)	14,530,848	500,000	3,092,865	8,416,035
សមមូលនឹងពាន់រៀល	**12,068,555**	**(6,855,795)**	**(44,402,656)**	**58,661,033**	**2,018,500**	**12,485,896**	**33,975,533**

ការវិភាគរំលោចតម្លៃសមស្របសម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ថេរ

ធនាគារ មិនបានកត់ត្រាបំណុលហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ថេរតាមតម្លៃសមស្រប ដោយភាពលម្អៀង ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍លទ្ធផលនោះទេ ហើយធនាគារក៏មិនមានឧបករណ៍ ហិរញ្ញវត្ថុនាចុងកាលបរិច្ឆេទនោះដែរ។ ដូច្នេះការផ្លាស់ប្តូរអត្រាការប្រាក់នាចុងកាលបរិច្ឆេទពុំមានផលប៉ះពាល់ដល់ប្រាក់ចំណេញ ឬ ខាតនោះទេ ។

(ឃ) ហានិភ័យសាច់ប្រាក់ងាយស្រួល

ហានិភ័យសាច់ប្រាក់ងាយស្រួល ទាក់ទងនឹងលទ្ធភាពរក្សានូវទ្រព្យសកម្មងាយស្រួលឲ្យបានគ្រប់គ្រាន់ ដើម្បីបំពេញការសន្យា និងកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដែលដល់កាលកំណត់សងដោយក្នុងតម្លៃដ៏សមហេតុផលមួយ ។

បន្ថែមពីលើការអនុវត្តយ៉ាងពេញលេញតាមតម្រូវការនៃសាច់ប្រាក់ងាយស្រួល អ្នកគ្រប់គ្រងធនាគារ បានត្រួតពិនិត្យយ៉ាងជិតដិតលើលំហូរសាច់ប្រាក់ចេញចូល និងចំនួនគំលាតតាមកាលវិសាន្តតាមរយៈ ការរាយការណ៍ជាប្រចាំ។ ការប្រែប្រួលនៃឥណទាន និងប្រាក់បញ្ញើរបស់អតិថិជន ត្រូវបានត្រួតពិនិត្យតាមដាន ហើយតម្រូវការសាច់ប្រាក់ងាយស្រួលត្រូវបានធ្វើការកែតម្រូវ ដើម្បីធានាថាទ្រព្យសកម្មងាយស្រួលមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបំពេញការសន្យា និងកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដល់កាល កំណត់សង ។

តារាងខាងក្រោមនេះ បង្ហាញពីការវិភាគនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុរបស់ធនាគារ ដោយធ្វើការចាត់ជាក្រុមតាមកាលវិសាន្តនៅសល់ក្នុងការសន្យាសង។

	រហូតដល់1 ខែ	1 - 3 ខែ	3 - 12 ខែ	1 - 5 ឆ្នាំ	5 ឆ្នាំ	គ្មានកំណត់	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017							
បំណុល	1,047,102	-	-	-	-	-	1,047,102
គណនីត្រូវទូទាត់សងសម្ព័ន្ធញាតិ	-	-	-	-	-	42,783	42,783
ប្រាក់កម្ចី	14,252	3,766,835	8,541,154	19,905,773	-	-	32,228,014
	1,061,354	3,766,835	8,541,154	19,905,773	-	42,783	33,317,899
សមមូលនឹងពាន់រៀល	**4,284,686**	**15,206,713**	**34,480,639**	80,359,606	-	**172,715**	134,504,359
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016							
បំណុល	813,434	-	-	-	-	-	813,434
គណនីត្រូវទូទាត់សងសម្ព័ន្ធញាតិ	-	-	-	-	-	115,836	115,836
ប្រាក់កម្ចី	-	4,311,037	21,535,104	3,034,732	-	-	28,880,873
	813,434	4,311,037	21,535,104	3,034,732	-	115,836	29,810,143
សមមូលនឹងពាន់រៀល	3,283,833	17,403,656	86,937,215	12,251,213	-	467,630	120,343,547

ធនាគារធ្វើការវិភាគកាលកំណត់សម្រាប់បំណុលហិរញ្ញវត្ថុដែលបង្ហាញពីកាលកំណត់កិច្ចសន្យានៅសល់។ ទោះជាយ៉ាងណា ធនាគារនូវតែត្រួតពិនិត្យលើទ្រព្យសកម្ម ដើម្បីគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួលក្នុងរយៈពេលតែមួយខែមុន ដោយសារតែធនាគារមានកម្ចីរយៈពេលខ្លីពីធនាគារនៅពេលណាដែលវាជួបប្រទះបញ្ហាសាច់ប្រាក់។

(ង) ការគ្រប់គ្រងដើមទុន

(i) បទប្បញ្ញត្តិដើមទុន

ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរបានបង្កើត និងត្រួតពិនិត្យនូវតម្រូវការដើមទុនរបស់ធនាគារជារួម។

គោលនយោបាយរបស់ធនាគារ គឺធានាឲ្យបាននូវមូលដ្ឋានដើមទុនរឹងមាំ ដើម្បីរក្សានូវទំនុកចិត្តទីផ្សារ និងដើម្បីធានាស្ថិរភាពនៃការអភិវឌ្ឍន៍យូរអង្វែងរបស់អាជីវកម្ម។ ផលប៉ះពាល់នៃកម្រិតដើមទុនលើ ភាគលាភម្ចាស់ហ៊ុន ក៏ត្រូវបានទទួលស្គាល់ ហើយធនាគារបានទទួលស្គាល់នូវតម្រូវការដើម្បីធានាឲ្យ បាននូវតុល្យភាពរវាងភាគលាភខ្ពស់ ដែលអាចនឹងកើតមានឡើងនូវបំណុលខ្ពស់ និងអត្ថប្រយោជន៍ និងការធានាដែលផ្តល់ដោយស្ថានភាពមូលធនល្អ ។

ធនាគារបានអនុលោមទៅតាមតម្រូវការដើមទុន ដែលបានកំណត់ដោយច្បាប់នៅក្នុងការិយបរិច្ឆេទ។

(ii) ការបែងចែកដើមទុន

ការបែងចែកដើមទុនរវាងប្រតិបត្តិការ និងសកម្មភាពជាក់លាក់ គឺត្រូវបានគ្រប់គ្រងដោយកម្រិតភាគលាភ ដែលទទួលបានពីការបែងចែកនោះ។ ដើមទុនដែលបានបែងចែកទៅតាមប្រតិបត្តិការ ឬសកម្មភាព នីមួយៗ ត្រូវផ្អែកទៅតាមដើមទុនដែលកំណត់ដោយច្បាប់ ។

២៤ តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

ធនាគារ ពុំមានឧបករណ៍ហិរញ្ញវត្ថុ ដែលត្រូវវាស់វែងតាមតម្លៃសមស្របនោះទេ ។

តម្លៃសមស្រប គឺជាតម្លៃដែលទ្រព្យសកម្មអាចប្តូរបាន ឬជាតម្លៃដែលបំណុល ត្រូវបានសងតាមតម្លៃទីផ្សារ។ ដោយសារតម្លៃទីផ្សារ ពុំអាចវាយតម្លៃបានដូច្នេះពុំមានតម្លៃសមស្របសម្រាប់វាយតម្លៃទ្រព្យសកម្ម និងបំណុលជាសារវន្តរបស់ធនាគារ ដែលត្រូវបង្ហាញឡើយ។

តម្លៃសមរម្យគឺផ្អែកលើការប៉ាន់ស្មានរបស់អ្នកគ្រប់គ្រងទៅលើទ្រព្យសកម្ម និងបំណុល។ តាមគំនិតរបស់គណៈគ្រប់គ្រង តួលេខនៃទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុ ដែលបានរួមបញ្ចូលនៅក្នុងតារាងតុល្យការ គឺជាការវាយតម្លៃសមហេតុផល នៃតម្លៃសមស្របរបស់ពួកគេ។

២៥ រយៈពេលខ្ចី និងវែង

គណៈគ្រប់គ្រងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើសាច់ប្រាក់ងាយស្រួល។ ព័ត៌មានអំពីរយៈពេលខ្លី និងរយៈពេលវែងនៃទ្រព្យសកម្ម និងបំណុលត្រូវបានលាតត្រដាងនៅក្នុងផ្នែកការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ។ ទ្រព្យ និងបរិក្ខារ ទ្រព្យសកម្មអរូបី ទ្រព្យសកម្មពន្ធពន្យារ គឺជាទ្រព្យសកម្មរយៈពេលវែង។ បំណុលពន្ធលើប្រាក់ចំណេញ គឺជាបំណុលរយៈពេលខ្លី។

២៦ ព័ត៌មានប្រៀបធៀប

តួលេខប្រៀបធៀបមួយចំនួនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ ដើម្បីអោយសមស្របទៅនឹងការបង្ហាញនៃ របាយការណ៍ហិរញ្ញវត្ថុក្នុងឆ្នាំបច្ចុប្បន្ន។

២៧ ព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទនៃរបាយការណ៍

នៅថ្ងៃទី 16 ខែកុម្ភៈ ឆ្នាំ 2018 ធនាគារជាតិនៃកម្ពុជាបានចេញសារាចរលេខ ធ7-018-001 ស្តីពីការអនុវត្តប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមែរមិន ដែលបញ្ជាក់ពីចំណាត់ថ្នាក់ និង សំវិធានធនលើអ៊ីមែរមិន សម្រាប់ឥណទានរយៈពេលខ្លីដូចខាងក្រោម៖

ចំណាត់ថ្នាក់	ចំនួនថ្ងៃដែលជំពាក់	សំវិធានធន
ធម្មតា	14 ថ្ងៃ ឬ តិចជាង	1%
ឃ្លាំមើល	15 ថ្ងៃ– 30 ថ្ងៃ	3%
ក្រោមស្តង់ដារ	31 ថ្ងៃ– 60 ថ្ងៃ	20%
ជាប់សង្ស័យ	61 ថ្ងៃ– 90 ថ្ងៃ	50%
បាត់បង់	91 ថ្ងៃ ឬ ច្រើនជាង	100%

បន្ថែមពីនេះ ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ត្រូវធ្វើសំវិធានធនលើធាតុក្រៅតារាងតុល្យការ ទៅតាមការណែនាំលម្អិតក្នុងសារាចរ។

ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

ÆON SPECIALIZED BANK (CAMBODIA) PLC.